# អ្នកនាំសារ

THE MESSENGER

ឆ្នាំគ្រួសារ ២០១៧-២០២០

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២ | សម្រាប់ខែ មីនា ឆ្នាំ ២០១៩ | តម្លៃលក់ ១០០០រៀល | លេខ #១១៨



## ក្រសួងថាកម្ពុជាអាចនាំចេញបន្លែខ្លះ! ប៉ុន្តែកសិករ...?

បើទោះបីជាការនាំចេញបន្លែវាមិនមានបរិមាណច្រើនក៏ដោយ ប៉ុន្តែក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអះអាងនៅក្នុងរបាយការណ៍មួយថា កម្ពុជាកាលពីឆ្នាំទៅ អាចនាំចេញបន្លែខ្លះទៅសហគមន៍អឺរ៉ុប។

> ទំព័រ ១០-១១



# គោរព និងការពារបរិស្ថានធម្មជាតិ ជាសកម្មភាពមួយនៃការកែប្រែចិត្តគំនិត

*ដោយ៖ លី សុវណ្ណា*

ព្រះសហគមន៍កាតូលិកក្នុងរយៈពេលនេះបានចូលក្នុងរដូវអប់រំពិសេស(រដូវត្រណម) ដែលមានរយៈពេល៤០ថ្ងៃមុនបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

ក្នុងរយៈពេល៤០ថ្ងៃនេះជាពេលវេលាពិសេស សម្រាប់គ្រីស្តបរិស័ទ ក្នុងការរៀបចំខ្លួន និងកែប្រែចិត្តគំនិតជាថ្មី យកចិត្តទុកដាក់នឹងជំនឿ អំពីទំនាក់ទំនងជាមួយព្រះជាម្ចាស់ ជាមួយបងប្អូន ជាដើម។

តាមទំនៀមទំលាប់ព្រះសហគមន៍កាតូលិក គ្រីស្តបរិស័ទត្រូវប្រព្រឹត្តឲ្យបានសមរម្យ ទាំងផ្លូវកាយ និងចិត្ត គឺ ត្រូវតមអាហារ យ៉ាងតិច នៅថ្ងៃបុណ្យរោយផេះ និងរៀងរាល់ថ្ងៃសុក្រ។ ប្តូររបៀបរស់នៅ របៀបទំនាក់ទំនងជាមួយបងប្អូន ជាមួយធម្មជាតិ។ ជៀសវៀងឲ្យបាននូវចិត្តលោភលន់ ចិត្តអាត្មានិយាយ។ យកចិត្តទុកដាក់អធិដ្ឋាន ស្តាប់ព្រះបន្ទូល និងនៅឲ្យកាន់តែជិតស្និទជាមួយព្រះយេស៊ូ។

ជាមួយគ្នានេះ ត្រូវតែទុកចិត្តលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដែលមានព្រះហឫទ័យមេត្តាករុណាចំពោះមនុស្សទាំងអស់ និងមួយទៀតគឺចេញសកម្មភាព មេត្តាករុណា បំពេញកិច្ចការសប្បុរសធម៌។ កិច្ចការទាំងនេះ គឺគ្រីស្តបរិស័ទគ្រប់រូបត្រូវតែយកចិត្តទុកដាក់អនុវត្តន៍បំផុត។

បងប្អូនជាទីស្រឡាញ់! ក្នុងធម្មទេសនាថ្ងៃបុណ្យរោយផេះជាថ្ងៃទី១ នៃរដូវត្រណម លោកអូលីវីយេអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ បានជំរុញឲ្យគ្រីស្តបរិស័ទខិតខំបង្ហាញវត្តមានរបស់ព្រះយេស៊ូ តាមរយៈសកម្មភាព ក្នុងជីវិតរស់នៅរបស់ម្នាក់ៗ ព្រោះគ្រីស្តបរិស័ទបានទទួលអគ្គសញ្ញាជ្រមុជទឹក គឺបានចូលក្នុងមហាគ្រួសាររបស់ព្រះជាម្ចាស់ (ព្រះសហគមន៍) និងក្លាយជាទូតរបស់ព្រះជាម្ចាស់។ មានតួនាទីឆ្លើយនូវចម្ងល់របស់បងប្អូនឯទៀត ថាតើព្រះជាម្ចាស់របស់អ្នកនៅឯណា? លោកថា ម្នាក់ៗត្រូវជ្រើសរើសយកសកម្មភាពមួយដែលខ្លួនត្រូវយកចិត្តទុកដាក់អនុវត្តន៍ជាក់ស្តែង ក្នុងរយៈពេល៤០ថ្ងៃនេះជាសកម្មភាពនៃសប្បុរសចំពោះបងប្អូនឯទៀតៗ និងធម្មជាតិផងដែរ។ យកចិត្តទុកដាក់ចំពោះបងប្អូនម្នាក់ក៏បាន។

ចំពោះសម្តេចប៉ាប្រ៉ង់ស៊ីស្កូ នៅក្នុងសារលិខិត សម្រាប់រដូវត្រណមដែលមានចំណងជើង ថា «អ្វីៗសព្វសារពើដែលព្រះអង្គបង្កើតមក កំពុងតែអន្ទះអន្ទែង ទន្ទឹងរង់ចាំពេលដែលព្រះជាម្ចាស់នឹងបង្ហាញបុត្ររបស់ព្រះអង្គ» ក្នុងសារនេះ លោកក៏បានជំរុញឲ្យមនុស្សទាំងអស់យកចិត្តទុកដាក់ និងបរិស្ថានធម្មជាតិ ដែលជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់។

យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ យើងទទួលប្រយោជន៍ពីអ្វីៗសព្វសារពើទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក។

លោកបន្តថា៖ «បាប» គឺការបង្អាក់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ ជាមួយនឹងបងប្អូនឯទៀតៗ និងរួមជាមួយអ្វីសព្វសារពើរ មានបរិស្ថានធម្មជាតិជាដើមដែលវាបាននៅជាប់ជានិច្ចក្នុងខ្លួនយើងម្នាក់ៗ។

ពេលយើងបំផ្លាញទំនាក់ទំនងរវាងយើងជាមួយបរិស្ថានធម្មជាតិ គឺផ្តាច់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែរ។ ព្រះជាម្ចាស់ប្រទានឲ្យយើងរស់នៅក្នុងបរិស្ថានល្អ តែបែជាមនុស្សធ្វើឲ្យក្លាយជាវាលរហោស្ថានទៅវិញ។

មនុស្សគិតថា ខ្លួនជាអ្នកបង្កើតអ្វីៗទាំងអស់ ហេតុនេះមានសិទ្ធិបំផ្លាញវា និងប្រើវាសម្រាប់ប្រយោជន៍អាត្មានិយម និងបំផ្លាញបងប្អូនឯទៀតៗបាន។

ពិភពលោកបច្ចុប្បន្ននេះ អាកាសធាតុមានការប្រែប្រួលយ៉ាងខ្លាំងមិនទៀងទាត់ ក្តៅៗខ្លាំង ត្រជាក់ៗខ្លាំង រញ្ជួយដី បាក់ស្រុតដី ភ្នំភ្លើង ទឹកជំនន់ ជាពិសេសមានភ្លៀង ព្យុះខុសរដូវ។ល។ តាមការប្រកាសរបស់ក្រសួងជំនាញនៃរាជរដ្ឋាភិបាលកម្ពុជា គឺកម្ពុជានៅពេលខាងមុខ នឹងកើនកំដៅខ្លាំងរហូតជាង៤០អង្សាផង។

យើងម្នាក់ៗអាចប្រព្រឹត្តល្អយ៉ាងណាខ្លះចំពោះធម្មជាតិ? ខ្ញុំទុកដាក់សម្រាម ថង់ផ្លាស្ទីកបែបណាខ្លះ? តើខ្ញុំបានបំផ្លាញបរិស្ថានក្នុងសកម្មភាពណាខ្លះ? តើខ្ញុំត្រូវកែប្រែទម្លាប់បំផ្លាញបរិស្ថាននេះបែបណា? ខ្ញុំគួរប្តូររបៀបទំនាក់ទំនងរបស់ខ្ញុំជាមួយបរិស្ថានធម្មជាតិបែបណាខ្លះ? តើការអាហាររបស់ខ្ញុំមានន័យដូចម្តេច បើខ្ញុំប្រើប្រាស់ថង់ផ្លាស្ទីក លើសលប់ និងបោះសម្រាមចោលគ្មានសណ្តាប់ធ្នាប់នោះ?

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

**ចាងហ្វាង : លោក លី សុវណ្ណា**
**សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩**
**ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ**
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# ការបោះឆ្នោតនៅថៃខែនេះ អាចជារបត់ថ្មី នៃលទ្ធិប្រជាធិបតីដ៏ផុយស្រួយមួយនៅក្នុងតំបន់

*ដោយ៖ អរិយបុត្រ*




ថ្ងៃអាទិត្យទី ២៤ ខែ មីនា ឆ្នាំ ២០១៩ គឺជាថ្ងៃប្រវត្តិសាស្ត្រមួយនៃប្រទេសថៃ ក្រោយពីយោធាបានធ្វើរដ្ឋប្រហារហើយបានចូលកាន់កាប់អំណាចដោយបង្កើតរដ្ឋាភិបាលយោធាតាំងពីខែឧសភា ឆ្នាំ២០១៤ មក។

នៅថ្ងៃនោះ ពិភពលោក និង ប្រជាជាតិនៅក្នុងតំបន់ ដោយរួមទាំងកម្ពុជានឹងចូលរួមតាមដានដំណើរវិវត្តន៍ទៅមុខនៃលទ្ធិប្រជាធិបតេយ្យដ៏ផុយស្រួយ និង សំបូរទៅដល់រដ្ឋប្រហារនៅក្នុងព្រះរាជាណាចក្រមួយនេះ ។ ចាប់តាំងពីចូលកាន់កាប់អំណាច មេដឹកនាំយោធានៃប្រទេសនេះ បានសន្យាម្តងជាពីរដង អំពីការរៀបចំការបោះឆ្នោត ដើម្បីស្តារលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែបានពន្យាពេលជាបន្តបន្ទាប់។ក្រោយរដ្ឋាភិបាលយោធាចូលមកដឹកនាំប្រទេសរាជាណាចក្រក្បែរខាងកម្ពុជាមួយនេះ បានសន្យានឹងរៀបចំការបោះឆ្នោត នៅឆ្នាំ ២០១៥ ប៉ុន្តែពន្យាពេលម្តង ហើយក្រោយមក អតីតប្រមុខកងទ័ពឧត្តមសេនីយ បាយុទ្ធ ចាន់អូចា បានសន្យានៅមុខអង្គការសហប្រជាជាតិជាថ្មី ថាការបោះឆ្នោតនឹងរៀបចំនៅខែ កញ្ញា ឆ្នាំ ២០១៦ តែការសន្យានេះប្រែជាខ្យល់ជាថ្មី ហើយ ក្រោយមកទៀត ក៏បានសន្យាជាថ្មីថា នឹងរៀបចំចុងឆ្នាំ២០១៧ ។ប៉ុន្តែនៅពេលទៅទស្សនកិច្ចនៅវ៉ាស៊ីនតោន កាលពីខែ តុលា ឆ្នាំ ២០១៧ នោះ លោកប្រាយុទ្ធ បានសន្យាជាថ្មីថារៀបចំការបោះឆ្នោត នៅខែ វិច្ឆិកា ឆ្នាំ ២០១៨ ប៉ុន្តែបានលើកពេលជាថ្មី ថាមកធ្វើនៅខែ កុម្ភៈ ឆ្នាំ ២០១៩ ក្រោយមកក៏ពន្យាពេលដល់ថ្ងៃទី ២៤ ខែ មីនា នេះតែម្តង។

លើកនេះគេសន្និដ្ឋានថាអាចជាការរៀបចំការបោះឆ្នោតមែនទែនហើយ ព្រោះលោកប្រាយុទ្ធ ខ្លួនឯងនេះក៏បានដាក់ឈ្មោះចូលរួមឈរឈ្មោះបោះឆ្នោតជាលើកទីមួយដែរ ក្រោយឡើងកាន់អំណាច ដោយរដ្ឋប្រហារ ខណៈដែលគណបក្សនយោបាយផ្សេងៗក៏បានដាក់បេក្ខភាពនាយករដ្ឋមន្ត្រីមករួចហើយដែរ។

ថ្មីៗនេះ គណកម្មាធិការជាតិរៀបចំការបោះឆ្នោតថៃ បានប្រកាសថា គណបក្សនយោបាយថៃទាំងអស់ បានដាក់បញ្ជីឈ្មោះបោះឆ្នោតដោយមានបេក្ខជនជានាយករដ្ឋមន្ត្រីចំនួន ៦៩រូប លើកលែង តែ ព្រះអង្គម្ចាស់ក្សត្រីអ៊ូប៊ុនរតនា ដែលជាព្រះរាមរបស់មហាក្សត្រថៃចេញ ក្រោយពេលដែលព្រះមហាក្សត្រថៃបានចេញរាជសារជំទាស់បេក្ខភាពនេះ ទោះបីជាបេក្ខភាពនេះ ព្រះអង្គម្ចាស់ក្សត្រីបានសព្វព្រះទ័យនៅក្នុងការឈរ និង លះបង់ពីខ្សែរព្រះរាជវង្សក៏ដោយ ។



*អតីតប្រមុខកងទ័ពឧត្តមសេនីយ បាយុទ្ធ ចាន់អូចា។*
*រូបភាព៖ The Japan Times*

ក្រៅពីលោក ប្រាយុទ្ធ ចេញ លោកអាភីស៊ិត វាចាជីវ៉ា មេដឹកនាំគណបក្សប្រជាធិបតេយ្យ ដែលជាអតីត នាយករដ្ឋមន្ត្រីមួយរូប និងគណបក្សដែលឡើងកាន់អំណាចតាមចលនាអាវលឿង ក៏បានប្រកាសចូលរួមដែរ ហើយ ខាងគណបក្សភឿថៃ ដែលជាគណបក្សមកពីចលនាអាវក្រហមលំអៀងទៅរកក្រុមនយោបាយលោក ថាកស៊ិន ស៊ីណាវ៉ាត់ត្រា ក៏បានដាក់បេក្ខភាពរួចរាល់ដែរ។

រហូតមកដល់ពេលនេះ គេនៅមិនទាន់ដឹងថា តើជោគវាសនា របស់គណបក្សថៃរក្សាជាតិ ដែលយកព្រះនាង អ៊ូប៊ុនរតនា ជាបេក្ខភាពនាយករដ្ឋមន្ត្រីរបស់បក្សនេះនឹងទៅជាយ៉ាងណាទេ ដោយសារតែមានញត្តិសុំឲ្យពិនិត្យករណីធម្មនុញ្ញភាពនៃគណបក្សនេះ ក្រោយយកខ្សែរព្រះរាជវង្សមកចូលរួមបោះឆ្នោត។ខណៈដែលគណបក្សនេះ គឺជាគណបក្សមួយទៀត ដែលជាគណបក្សដែលប្រកាសពីស្វាមីភ័ក្រ និងអតីតនាយករដ្ឋមន្ត្រី ថាក់ស៊ីន ផងដែរនោះ។

លោក ប្រាយុទ្ធ ត្រូវបានគេដឹងថា គឺតំណាងឲ្យគណបក្សដែលបង្កើតឡើងដោយរដ្ឋាភិបាលយោធាគឺគណបក្ស ប៉ាឡាំង ប្រជាជាតិ។ លោកប្រាយុទ្ធនឹងចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតជាលើកទី១ ដើម្បីចូលរួមដណ្តើមអសនៅក្នុងសភា ចំនួន ៥០០ កន្លែង និងព្រឹទ្ធសភា២៥០អសនៈទៀត និងអាចក្លាយជានាយករដ្ឋមន្ត្រី។

នេះគឺជាការបោះឆ្នោតមួយ ដែលនឹងរៀបចំតាមលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែអ្នកវិភាគមួយចំនួន បានវិភាគថា វាអាច តែវាក៏មិនអាច ដោយសារតែមុនពេលបោះឆ្នោត រដ្ឋាភិបាលយោធា បានធ្វើវិសោធកម្មច្បាប់ ជាបន្តបន្ទាប់ ហើយមានលក្ខណៈស្មុគស្មាញ។

តាមរយៈមូលដ្ឋាននៃការវិភាគនេះ គេរំពឹងថា វាគឺជាការផ្តល់ឱកាស និងភាពងាយស្រួលមែនទែន សម្រាប់លោក ប្រាយុទ្ធ នៅក្នុងការបន្តដឹកនាំក្រុមយោធាកាន់កាប់អំណាចតាមបែបស៊ីវិលនេះបន្តទៀត។

លោក ប្រាយុទ្ធ ដែលបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីតាមរដ្ឋប្រហារយោធាលើកទី ១២ នៅក្នុងប្រវត្តិសាស្ត្រនៃរដ្ឋប្រហារ ចាប់តាំងពីប្រទេសបានផ្លាស់ប្តូររដ្ឋធម្មនុញ្ញ ពីរាជាធិបតេយ្យ នៅក្នុងឆ្នាំ១៩៣២ មក បានរៀបចំជើងព្រួលយ៉ាងច្បាស់លាស់មួយ។ តាមការរៀបចំ គឺថា សមាជិកក្រុមប្រឹក្សាជាតិ ដើម្បីសន្តិភាព និង សណ្តាប់ធ្នាប់ ដែលបង្កើតឡើងដោយរដ្ឋប្រហារយោធានោះ បានរៀបចំតាមច្បាប់រដ្ឋធម្មនុញ្ញ ដោយឲ្យមេដឹកនាំយាធាចូលកាន់កាប់តំណែងព្រឹទ្ធសភាទាំង២៥០អសនដូច្នេះ នៅក្នុងការបោះឆ្នោតជាតិខាងមុខនេះ គឺលោក ប្រាយុទ្ធ មានភាពងាយស្រួលបំផុតនៅក្នុងការរក្សា តំណែងរបស់លោក ដែលខុសប្លែកពីបេក្ខភាពនាយករដ្ឋមន្ត្រីឯទៀត។

បេក្ខភាពនាយករដ្ឋមន្ត្រី៦៨ នាក់ផ្សេងទៀត គឺក្រៅពីប្រកួតនៅក្នុងការបោះឆ្នោតថ្នាក់ជាតិនេះហើយនោះ នៅពេលឈ្នះ ពួកគេក៏ត្រូវការនូវការគាំទ្រពីព្រឹទ្ធសភាដែលយោធាកាន់កាប់នោះបន្ថែមទៀត ដូច្នេះ មិនជារឿងងាយស្រួលនោះទេ ។ សម្រាប់លោក ប្រាយុទ្ធ គឺលោកត្រូវការតែការឈ្នះនៅក្នុងសភាត្រឹមតែ ១២៦ អសនៈ គឺនឹងមានការគាំទ្រពីព្រឹទ្ធសភា ២៥០ សម្លេងដោយស្វ័យប្រវត្តិ ខណៈដែលបេក្ខភាពដទៃទៀត គឺត្រូវការគាំទ្រពីសមាជិកសភា និងព្រឹទ្ធសភា រហូតដល់ទៅ ៣៧៦ សម្លេង ទើបអាចកាន់កាប់តំណែងជាប្រមុខរដ្ឋាភិបាលថៃថ្មីនេះបាន៕

# ផ្លូវគមនាគមន៍ថ្មី កាន់តែមានសភាពជាសរសៃឈាម ហើយនៅកម្ពុជានាពេលបច្ចុប្បន្ន



ក្រោយពេលសង្គ្រាមបានបញ្ចប់បណ្តាញផ្លូវគមនាគន៍នៅកម្ពុជា កំពុងតែកសាង និងតភ្ជាប់ពីមួយ ទៅមួយប្រៀបបាននឹងសរសៃឈាមនៅក្នុងខ្លួនមនុស្ស រហូតអាចធ្វើឲ្យយើងវង្វេងបើកចុះបើកឡើងកាត់ពីខេត្តមួយទៅខេត្តមួយ ហើយមកដល់រាជធានីភ្នំពេញដោយមិនចាំបាច់បកត្រលប់ក្រោយ វិញឡើយ ។

*ដោយ៖ អរិយបុត្រ*

លោក ជាគឹមសាត ដែលជាអ្នកបើករថយន្តតាក់ស៊ីមួយរូបនៅលើកំណាត់ផ្លូវភ្នំពេញ កំពង់ធំ ខេត្តព្រះវិហា នឹង ស្ទឹងត្រែង បានអះអាងថា ផ្លូវឥឡូវមានខ្វាត់ខ្វែង ស្ទុះមួយទៅមួយទៀតបាន តែ ប្រយ័ត្នវិលមុខបើកចុះបើកឡើងវង្វេងរត់មកកន្លែងដើមវិញ ដោយសារតែផ្លូវថ្នល់ឥឡូវនេះ នៅក្នុង ព្រៃក៏មានផ្លូវដែរ។

លោកបានបន្តទៀតថា ពីមុនបើចង់បើកទៅខេត្តស្ទឹងត្រែង ដាច់ខាតគឺត្រូវតែបើកកាត់តាម កំពង់ចាម រួចបន្តទៅក្រចេះតាមផ្លូវជាតិលេខ ៧ ហើយកាត់ក្រចេះ បន្តទៅ អូរពងមាន់ រួចហើយទើបបានបទទៅ ខេត្តស្ទឹងត្រែង។

ក្រោយមកទៀត ពេលមានស្ពានព្រែកតាមាក់ គេអាចបើកតាមផ្លូវជាតិលេខ ៨ ហើយកាត់ តាមឆ្លូង ទៅដល់ក្រចេះ ក៏បាន តាមផ្លូវជាតិលេខ ៧ ក៏បាន ប៉ុន្តែឥឡូវ មិនចាំបាច់កាត់តាមនោះទេ គឺគេអាចទៅតាមផ្លូវជាតិលេខ ៦ អា កាត់តាមខេត្តកំពង់ធំ ហើយតាមផ្លូវឆ្ពោះទៅ ខេត្តព្រះវិហា តាមផ្លូវជាតិលេខ ៦២ រួចបន្តតាមផ្លូវជាតិ ២១៣ មកដល់ ភ្នំដែក គេអាចនឹងបន្តទៅតាមផ្លូវបំបែកទៅស្រុកកំរៀង នៅក្នុងខេត្តព្រះវិហា រួចបន្តទៅ ស្រុកជ័យសែន តាម ផ្លូវជាតិថ្មីដែលកំពុងតែសាងសង់ គឺផ្លូវជាតិលេខ ៦៤ ។

លោកបញ្ជាក់ថា៖ «តាមផ្លូវនេះ រាងលំបាកប្រមាណជា ២០ គីឡូម៉ែត្រ ដោយសារវាមិនទាន់ សាងសង់រួច ដីនៅហុយ ហើយ ផ្លូវចាស់វាតូច ស្ពានក៏តូច ប៉ុន្តែគេបានកសាងផ្លូវជាតិធំ ពីខេត្ត ស្ទឹងត្រែង មក»។

លោកបានបន្តថា៖ «ធ្វើជាអ្នករត់តាក់ស៊ី ដាច់ខាតត្រូវតែស្គាល់ផ្លូវច្រើន ពីព្រោះវាចំណេញសាំង កាត់បន្ថយចម្ងាយបើកបរ។ បើស្គាល់ផ្លូវដដែលៗ គឺ ពិបាករកស៊ីណាស់ ហើយ រកស៊ីមិនទាន់គេ ទៀត»។

តាមការអះអាងរបស់អ្នកបើកបរតាក់ស៊ីរូបនេះ បានអះអាងថា សព្វថ្ងៃកំណាត់ផ្លូវជាតិលេខ ៦៤ នេះ គឺវាពិបាកនៅក្នុងការបើកបរបន្តិចដោយសារផ្លូវចាស់មួយកំណាត់ដែលនៅសល់ រាងតូច ស្ពានវាចាស់ៗ ហើយផ្លូវថ្មីគឺគេកំពុងតែសាងសង់ ធ្វើឲ្យវាហុយខ្លាំង។ ពេលបើកកាត់ អ្នកដំណើរដែលមិនដែល គឺមានអារម្មណ៍ភ័យខ្លាចដោយសារតែ វានៅមិនទាន់មានផ្ទះប្រជាពលរដ្ឋច្រើនទេ គឺវាកសាងកាត់ព្រៃ កាត់ចំការ ប៉ុន្តែក្រោយពេលដែលផ្លូវបានឈូសឆាយចេញរូបចេញរាងហើយនោះ គឺនៅពេលនេះមានប្រជាជនមួយចំនួន ចាប់ផ្តើមមកតាំងទីលំនៅតាមបណ្តោយផ្លូវនេះជាបណ្តើរៗហើយ។

លោកបានអះអាងថា៖ «ខ្ញុំហ៊ាននិយាយថា មិនយូរទេ តែមានផ្លូវមានផ្ទះហើយ ណាមួយទៀត បង្គោលភ្លើង ទូរស័ព្ទអី ត្រូវគេអូសកាត់តាមបណ្តោយផ្លូវនោះអស់ហើយ» ។

លោក លី ពូលិត ជាអ្នកដំណើរមួយរូប បានមានប្រសាសន៍ថានៅទីប្រជុំជនភ្នំដែក នៅក្នុងស្រុក កំរៀង ខេត្តព្រះវិហា ថា ផ្លូវថ្នល់ឥឡូវនេះច្រើនឆ្វាត់ឆ្វែង ពេញតែប្រទេស ។ មកដល់កំពង់ធំ ចង់ទៅ ពោធិសាត់ ចង់ទៅ ណា សឹងតែមានគ្រប់ផ្លូវ ។

លោកបានបន្តទៀតថា នៅក្នុងនាមលោកជាអ្នករកស៊ីជាមួយនឹងផលិតផលកសិកម្ម ដូចជា ដំឡូងមី គ្រាប់ស្វាយចន្ទី និងកៅស៊ូ ជាដើម គឺលោកបានបើកសឹងតែសព្វផ្លូវ នៅក្នុងខេត្តកំពង់ចាម កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនៈគីរី។ លោកថាកន្លែងខ្លះមិនមានផ្លូវជាតិ ទេ ប៉ុន្តែមានផ្លូវគ្រួសក្រហម ផ្លូវលំ ផ្លូវភូមិ តភ្ជាប់គ្នា ពីមួយទៅមួយ ពេញព្រៃពេញភូមិ យើងអាចធ្វើដំណើរបាន។

រហូតមកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាមានបណ្តាញផ្លូវថ្នល់រាប់ពាន់គីឡូម៉ែត្រ ហើយតភ្ជាប់ពេញ ផ្ទៃប្រទេស។

ក្រសួងសាធារណការ និងដឹកជញ្ជូនបានឱ្យដឹងថា គិតការស្ថាបនាផ្លូវជាតិ និងផ្លូវខេត្តនៅក្នុងប្រទេសមាន មានប្រវែងសរុបចំនួន១៦.២៩២



គីឡូម៉ែត្រ ក្នុងនោះចាក់កៅស៊ូ និងបេតុងបានប្រវែង៨.៦២០គីឡូម៉ែត្រ ត្រូវនឹង៥២,៩១ ភាគរយ នៃប្រវែងផ្លូវសរុប។

ប្រភពដដែលបានបន្តទៀតថា ចំពោះការស្ថាបនាផ្លូវជាតិកម្រិត១ មានចំនួន៩ខ្សែ ប្រវែង២.២៥៤ គីឡូម៉ែត្រ ចាក់កៅស៊ូ និងបេតុងបាន១០០ភាគរយ។ ផ្លូវជាតិកម្រិត ២ ចំនួន៦៦ខ្សែ ប្រវែង ៥.០០៧ គីឡូម៉ែត្រ ចាក់កៅស៊ូ និងបេតុងបាន៧២,៣០ភាគរយ។ ចំណែកផ្លូវខេត្តមាន ចំនួន ៥២៨ខ្សែ ប្រវែង ៩.០៣១គីឡូម៉ែត្រ ចាក់កៅស៊ូ និងបេតុងបាន៣០,៤០ភាគរយ។

ក្រៅពីនេះ ទាំងក្រសួង និងរាជរដ្ឋាភិបាលក៏កំពុងតែសិក្សាអំពីកសាងបណ្តាញគមនាគមន៍ជាច្រើនកន្លែងថែម ទៀត ដើម្បីបង្កើតការតភ្ជាប់ ដើម្បីសម្រួលការធ្វើដំណើរ ការដឹកជញ្ជូន ការដោះដូរពាណិជ្ជកម្ម និងទេសចរណ៍ ជាដើម៕

# កម្ពុជាត្រូវការថវិកាយ៉ាងហោចណាស់ ៤០៦ លានដុល្លារទៀតដើម្បីបោសសំអាតមីនដែលនៅសេសសល់

ផ្អែកតាមលទ្ធផលដែលបានមកពីការស្រាវជ្រាវនូវចំការមីនដែលមានមូលដ្ឋាននៅទូទាំងប្រទេសបានបង្ហាញថា កម្ពុជានៅមានផ្ទៃដីសង្ស័យថាមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោមលាតសន្ធឹងប្រមាណជា ១៩៧០គីឡូម៉ែត្រក្រឡាទៀត។ នេះបើយោងតាមតួលេខដែលប្រកាសដោយ អាជ្ញាធរមីនកម្ពុជា។



សង្គ្រាមបានបន្សល់ទុកនូវគ្រាប់មីន និងកាកសំណល់នៃគ្រឿងផ្ទុះ។ រូបភាព៖ អាជ្ញាធរមីន

*ដោយ៖ អរិយបុត្រ*

តាមការប៉ាន់ប្រមាណរបស់ស្ថាប័ននេះ ដើម្បីបោសសំអាតមីន និងកាកសំណល់នៃគ្រឿងផ្ទុះនៅសេសសល់ពីសម័យសង្គ្រាមស៊ីវិលនៅកម្ពុជា និងតំបន់ឥណ្ឌូចិនចាប់តាំងពីដើមទសវត្សរ៍នៃឆ្នាំ១៩៧០ ដល់ចុងទសវត្សរ៍នៃឆ្នាំ ១៩៩០ មកនោះនឹងត្រូវការថវិកាប្រមាណ ៤០៦ លានដុល្លារអាមេរិក ដើម្បីបំពេញកិច្ចការនេះ រហូតដល់ប្រមាណជាឆ្នាំ ២០២៥ ។

ប្រភពដដែលបានបន្តថា គិតមកដល់ឆ្នាំ២០១៩ សកម្មភាពបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមជាលក្ខណៈមនុស្សធម៌នៅកម្ពុជាមានរយៈពេល ២៧ ឆ្នាំមក ហើយដោយពីឆ្នាំ ១៩៩២ ដល់ខែធ្នូ ឆ្នាំ ២០១៨ កម្ពុជាបានសម្រេចបោសសំអាតដីដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះបានជាង ១៨០២ គីឡូម៉ែត្រក្រឡាជូនប្រជាពលរដ្ឋសម្រាប់កសាងភូមិដ្ឋានធ្វើស្រែចម្ការកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា។

នៅក្នុងរយៈពេលនៃការបោសសំអាតមីននោះ អ្នកជំនាញបោសសំអាតមីននៅកម្ពុជាបានរកឃើញ និងកំទេចចោលនូវគ្រាប់មីនប្រឆាំងមនុស្សចំនួន ១.០៦២.៦៦១គ្រាប់, មីនប្រឆាំងរថក្រោះចំនួន២៤.៨៣២ គ្រាប់និងសំណល់ជាតិផ្ទុះពីសង្គ្រាម ២.៧៦៧.០២០ គ្រាប់ ព្រមទាំងបានធ្វើឲ្យចំនួនជនរងគ្រោះធ្លាក់ចុះពី ៤.៣២០ នាក់ក្នុងឆ្នាំ ១៩៩៦ មកត្រឹម ៥៨ នាក់ នៅឆ្នាំ២០១៨កន្លងទៅ។ ទន្ទឹមនឹងនេះ គ្រោះថ្នាក់ដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោមក៏នៅតែបង្កឲ្យប្រជាពលរដ្ឋធ្លាក់ខ្លួនពិការស្លាប់បាត់បង់ជីវិតមនុស្ស សត្វពាហនៈ និងខូចខាតទ្រព្យសម្បត្តិអស់ជាច្រើន។

ទាក់ទិននឹងកិច្ចការបោសសំអាតមីន និងគ្រាប់មិនទាន់ផ្ទុះនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជាក៏បានបញ្ចេញសារមួយផងដែរ កាលពីចុងខែ កុម្ភៈក្នុងឱកាសនៃទិវាយល់ដឹងអំពីមីនដែលប្រារព្ធទៅនៅថ្ងៃទី ២៤ ខែកុម្ភៈ លើកទី ២០ ។

នៅក្នុងសារនោះ សម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងថា ខួបលើកទី ២០ នៃទិវាជាតិយល់ដឹងអំពីមីនដើម្បីរំលឹកប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា ជាពិសេសបងប្អូនជនរួមជាតិ ដែលរស់នៅក្នុងតំបន់រងផលប៉ះពាល់ដោយសារមីនសំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះគ្រោះថ្នាក់ដែលបង្កឡើងដោយសារគ្រាប់ទាំងនោះ។

សម្តេចតេជោហ៊ុន សែន បានចែករំលែកថា គ្រាប់មីនសំណល់ជាតិផ្ទុះពីសង្គ្រាមនិងគ្រាប់បែកចង្កោមដែលជាកេរ្តិ៍ដំណែលបន្សល់ទុកពីសង្គ្រាមឥណ្ឌូចិន និងជម្លោះផ្ទៃក្នុងកម្ពុជាអស់រយៈពេលជាង ៣ ទសវត្សរ៍មិនត្រឹមតែបង្កសោកនាដកម្មដ៏ធ្ងន់ធ្ងរចំពោះអាយុជីវិត សុខភាព ប្រជាពលរដ្ឋរបស់យើងប៉ុណ្ណោះទេ តែថែមទាំងជាឧបសគ្គសម្រាប់ការស្តារ និងអភិវឌ្ឍជីវភាពគ្រួសារ និងសេដ្ឋកិច្ចជាតិទៀតផង។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្តថា ដើម្បីដោះស្រាយបញ្ហារាំងស្ទះនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យសកម្មភាពមីនជាគោលដៅទី ១៨ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ និងបញ្ចូលវិស័យនេះជាធាតុមួយដ៏សំខាន់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន។ ក្រោមនយោបាយឈ្នះឈ្នះនៅឆ្នាំ ១៩៩៨ កម្ពុជាទទួលបានសន្តិភាពពេញលេញទូទាំងប្រទេសដែលអនុញ្ញាតឲ្យរាជរដ្ឋាភិបាលមានលទ្ធភាពគ្រប់គ្រងចាត់ចែងការងារវិស័យសកម្មភាពមីននៅគ្រប់តំបន់ដែលរងការគំរាមកំហែងដោយសារគ្រាប់ទាំងនោះប្រកបដោយប្រសិទ្ធភាព។



សកម្មភាពនៃការបោសសំអាតមីនទាពេលកន្លងមក។ រូបភាព៖ អាជ្ញាធរមីន

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្តថា ដើម្បីបន្តដោះស្រាយនូវបញ្ហាគំរាមកំហែងទាំងឡាយដែលបន្សល់ទុកដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម រាជរដ្ឋាភិបាលកម្ពុជាទើបតែអនុម័តនូវផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ឆ្នាំ២០១៨-២០២៥ ក្នុងគោលបំណងបំផ្លាញចោលគ្រាប់លាក់មុខទាំងនោះឲ្យរួចរាល់នៅត្រឹមឆ្នាំ ២០២៥ ឆ្ពោះទៅរកកម្ពុជាមួយដែលគ្មានមីននៅឆ្នាំ ២០២៥។

សម្តេចតេជោក៏បានអំពាវនាវដល់អាជ្ញាធរ រួមមានអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ ប្រតិបត្តិករសកម្មភាពកំចាត់មីនជាតិអន្តរជាតិ និងដៃគូអភិវឌ្ឍព្រមទាំងប្រជាពលរដ្ឋ បង្កើត និងពង្រីកបណ្តាញសហគមន៍អប់រំយល់ដឹងអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមគ្រប់ភូមិ ឃុំ ស្រុក, ត្រូវរួមសហការលើកទឹកចិត្តដល់ប្រតិបត្តិករសកម្មភាពមីននិងអង្គការពាក់ព័ន្ធដើម្បីគាំទ្រ និងជំរុញការអនុវត្តកម្មវិធីអប់រំមីនដល់ប្រជាពលរដ្ឋ, ពង្រឹងកិច្ចសហប្រតិបត្តិការជាតិអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ចូលរួមឲ្យបានខ្លាំងក្លាថែមទៀតក្នុងការជួយកាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះ ។ល។




គ្រាប់មីនដែលនៅសេសសល់ពីសង្គ្រាម។ រូបភាព៖ អាជ្ញាធរមីន



# រាជរដ្ឋាភិបាលកម្ពុជារំលឹកជាថ្មីអំពី គ្រោះរាំងស្ងួតនៅក្នុងឆ្នាំនេះ

**ប្រមុខរាជរដ្ឋាភិបាលនិងអ្នកជំនាញនៃក្រសួងធនធានទឹក និងឧត្តុនិយមបានរំលឹកដដែលជាថ្មីម្តងទៀតសូមឲ្យមានការយកចិត្តទុកដាក់រឿងបញ្ហាគ្រោះរាំងស្ងួតដែលអាចកើតមានឡើងនៅក្នុងប្រទេស នៅឆ្នាំនេះ ដោយសារតែប្រទេសស្ថិតនៅក្រោមឥទ្ធិពលនៃបាតុភូតអាកាសធាតុអែលនីណូ។**

*រូបភាព៖ សហការី*

*ដោយ៖ អរិយបុត្រ*

តាមការព្យាករណ៍អាកាសធាតុរបស់ក្រសួងធនធានទឹក និងឧត្តុនិយមដែលបានប្រកាសជាបន្តបន្ទាប់បានឲ្យដឹងថា បច្ចុប្បន្ននេះ សីតុណ្ហភាពនៅក្នុងប្រទេសគឺនៅក្នុងរង្វង់ ៣៨ អង្សារសេ ហើយក្រសួងនេះបានព្យាករណ៍ថា កម្រិតសីតុណ្ហភាពនេះនឹងបន្តឡើងរហូតដល់ទៅ៤២ អង្សាសេឯណោះ។

ខណៈពេលដែលសីតុណ្ហភាពឡើងដល់ត្រឹមកម្រិត ៣៨ អង្សាសេនេះក្រសួងធនធានទឹក និងឧត្តុនិយមបានប្រកាសថា មានតំបន់មួយចំនួននៅក្នុងខេត្តចំនួន៨ គឺកំពុងតែជួបវិបត្តិនៃគ្រោះរាំងស្ងួតនេះបណ្តើរៗហើយ។

លោក ចាន់ យុត្ថា អ្នកនាំពាក្យ និងជារដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយមបានប្រាប់អ្នកសារព័ត៌មានជាបន្តបន្ទាប់ថា នៅក្រោមឥទ្ធិពលនៃបាតុភូតអែលនីណូនេះ ប្រភពទឹកមួយចំនួន ដូចជាអូរ ស្ទឹង បឹង ព្រែក កំពុងតែរីងស្ងួតហួតហែងជាបណ្តើរៗ ហើយល្បឿននៃការរីងស្ងួតនោះទៀតសោតក៏លឿនផងដែរ។

លោកបានបន្តថា ខេត្តដែល មានបញ្ហាខ្វះទឹកប្រើប្រាស់ដោយកន្លែងបានកើនដល់៨ហើយ ដោយរួមមានខេត្តកោះកុង បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ និងខេត្តព្រៃវែង។

លោកបានអះអាងថា ជាធម្មតានៅក្នុងរង្វង់ខែកុម្ភៈនេះ សីតុណ្ហភាពនៅកម្ពុជាគឺនៅក្នុងរង្វង់ត្រឹមតែ ៣៣ ទៅ ៣៤ អង្សាសេប៉ុណ្ណោះ ប៉ុន្តែឥឡូវវាបានហក់ឡើងពី ៣៨ ទៅ ៣៩ អង្សាសេ ហើយទម្រាំដល់ខែមេសាដែលតែងតែចំណាំក្តៅបំផុតនោះ គឺអាចឡើងដល់ ៤២ អង្សាសេ។

ដោយសារតែអាកាសធាតុក្តៅខ្លាំងបែបនេះ ក្រសួងធនធានទឹក និងឧត្តុនិយម បានចេញសេចក្តីជូនដំណឹងជាបន្តបន្ទាប់ដើម្បីឲ្យប្រជាពលរដ្ឋ និងអាជ្ញាធរពាក់ព័ន្ធត្រូវត្រៀមខ្លួនដោះស្រាយបញ្ហានេះ។ ដោយឡែក រាជរដ្ឋាភិបាលកម្ពុជា ក៏បានចេញសារាចរណ៍មួយរួចហើយដែរ ទាក់ទងនឹងបញ្ហាអាកាសធាតុដ៏ក្តៅខ្លាំងនេះ។

បើយោងតាមសារាចរណ៍ បានឲ្យដឹងថា ដោយយោងទៅតាមការព្យាករណ៍របស់ក្រសួងធនធានទឹក និងឧតុនិយមដែលបង្ហាញថា នៅដើមឆ្នាំ២០១៩នេះ កម្ពុជានឹងទទួលរង( ដោយប្រយោល )ពីឥទ្ធិពលបាតុភូតអែលនីណូ ( El Nino ) នោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំឲ្យការងារបង្កបង្កើនផលស្រូវប្រាំងឆ្នាំ២០១៩នេះ ធ្វើបានតែមួយដងប៉ុណ្ណោះ ដោយមិនអាចធ្វើស្រូវប្រាំងលើកទីពីរបានទេបើទោះបីជាទឹកនៅតាមបណ្តាអាងដែលបានរក្សាទុក និងកន្លែងមួយចំនួនដែលមានទឹកជាធម្មជាតិក៏ដោយ។ រាជរដ្ឋាភិបាលបានណែនាំឲ្យប្រជាពលរដ្ឋ និងអាជ្ញាធរគួរគប្បីរក្សាទឹកទាំងនោះទុកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងការដាំដំណាំរួមផ្សំផ្សេងទៀតក្រៅពីស្រូវ។

ក្នុងសារាចរណែនាំរបស់រាជរដ្ឋាភិបាលនេះ បានបញ្ជាក់ថា ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមចាត់វិធានការរក្សាទឹកទុកឲ្យបានល្អ ដើម្បីផ្គត់ផ្គង់សម្រាប់តែការប្រើប្រាស់ប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់ពេលមានភ្លៀងធ្លាក់ជាធម្មតាឡើងវិញ ។ ក្រសួង ស្ថាបន័ពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវត្រៀមលក្ខណៈជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះធម្មជាតិនានាដូចជាខ្យល់កន្ត្រាក់ជាដើម៕

ប្រភពដដែលបានបន្តទៀតថា ក្រោមឥទ្ធិពលនៃបាតុភូតនេះនឹងបង្កឲ្យអាកាសធាតុនៅកម្ពុជានារដូវប្រាំងនេះ ពិសេសក្នុងខែមេសា និងខែឧសភា មានសភាពក្តៅហួតហែង និងសីតុណ្ហភាពអតិបរមានៅពេលខ្លះ អាចហក់ឡើងដល់ពី៤០ទៅ៤២ អង្សាសេ មានភ្លៀងកក់ខែតិច មានបាតុភូតផ្គររន្ទះ និង ខ្យល់កន្ត្រាក់កើតឡើងច្រើនរដូវវស្សាមកដល់យឺតជាងបណ្តាឆ្នាំកន្លងទៅ។ល។

ថ្លែងនៅក្នុងពិធីជួបសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត ប្រមាណជិត ១២.០០០ នាក់ ដែលប្រារព្ធធ្វើឡើងនាព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលពាណិជ្ជកម្មមួយស្ថិតនៅភូមិព្រៃកា ឃុំឆក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល សម្តេចតេជោ ហ៊ុន សែន បានថ្លែងរំលឹកជាថ្មី បន្ទាប់ពីបានថ្លែងបែបនេះ នៅក្រសួងមហាផ្ទៃថា សូមប្រុងប្រយ័ត្ននឹងគ្រោះរាំងស្ងួតនៅក្នុងឆ្នាំនេះ ។

សម្តេចតេជោ ហ៊ុន សែន បានអំពាវនាវដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន សូមផ្តល់នូវការជូន ដំណឹងនឹងពន្យល់ប្រជាពលរដ្ឋជាកសិករ សូមកុំបង្កបង្កើនផលស្រូវប្រាំងជាលើកទីពីរនៅរដូវប្រាំងនេះ ដោយសារតែក្តីបារម្ភអំពីកង្វះខាតទឹក ។

សម្តេចតេជោ ហ៊ុន សែន បានស្នើសុំប្រជាពលរដ្ឋកសិករសូមកុំឲ្យធ្វើស្រែច្រើនដងនៅឆ្នាំនេះ ដោយសារឆ្នាំនេះនឹងមិនមានទឹកគ្រប់គ្រាន់នោះទេ៕



*គោយន្តប្រើសម្រាប់បូមទឹកនារដូវប្រាំង ខណៈទឹកមិននៅសល់ច្រើននោះឡើយ។ រូបភាព៖ សហការី*



រូបភាពតំណាង

# អង្គការអន្តរជាតិមួយព្រមានរឿងការ បៀតបៀនតាមប្រព័ន្ធអ៊ីនធឺណែត

**អង្គការយូនីសេហ្វ ដែលជាស្ថាប័នអន្តរជាតិ និងជាទីភ្នាក់ងារមួយនៃអង្គការសហប្រជាជាតិ បានអំពាវនាវឱ្យមានសកម្មភាពរួមគ្នាទប់ស្កាត់ការរករឿងឈ្លោះ និងបៀតបៀនលើយុវជនកម្ពុជា ដែលកំពុងប្រើប្រាស់អ៊ីនធឺណែត។ អង្គការនេះបានលើកឡើងថា ៣០ឆ្នាំក្រោយពីការអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងការបង្កើតប្រព័ន្ធអ៊ីនធឺណែត គឺដល់ពេលវេលាក្នុងការពិនិត្យមើលឡើងវិញនូវការយកចិត្តទុកដាក់អំពីសិទ្ធិប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់កុមារ។**

*ដោយ៖ អរិយបុត្រ*

អង្គការយូនីសេហ្វបាន ប្រកាសឲ្យដឹងជាមុនអំពីគ្រោះថ្នាក់ដែលបង្កឡើងដោយអំពើហិង្សាការរករឿងឈ្លោះ និងការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណែត ចំពោះយុវជន ៨៥,៧ ភាគរយ ដែលមានអាយុចាប់ពី១៥ ទៅ ២៥ឆ្នាំ ដែលកំពុងប្រើប្រាស់អ៊ីនធឺណែតនៅកម្ពុជា និងបានអំពាវនាវឱ្យមានសកម្មភាពរួមគ្នា ដើម្បីឆ្លើយតប និងទប់ស្កាត់អំពើហិង្សាលើកុមារ និងយុវជននៅតាមប្រព័ន្ធអ៊ីនធឺណែត។

ប្រភពដដែលបានបន្តថា បើតាមទិន្នន័យពីយូណេស្កូ អំពីប្រេវ៉ាឡង់នៃការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណែត នៅក្នុងប្រទេសដែលមានចំណូលខ្ពស់ ភាគរយនៃកុមារ និងក្មេងជំទង់ដែលរងផលប៉ះពាល់ពីការរករឿងឈ្លោះតាមប្រព័ន្ធអ៊ីនធឺណែត មានចាប់ពី៥ រហូតដល់ ២១ភាគរយ ហើយកុមារីហាក់បីដូចជាទទួលរងគ្រោះពីការធ្វើបាបតាមប្រព័ន្ធអ៊ីនធឺណែតច្រើនជាងកុមារា។ ដោយឡែកនៅកម្ពុជា ក្នុងចំណោមក្មេងស្រីអាយុពី១៥ ទៅ ២៤ឆ្នាំទាំងអស់ មាន ៨៤,៤ ភាគរយ កំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែត ហើយសម្រាប់កុមារាដែលស្ថិតក្នុងក្រុមអាយុដូចគ្នានេះគឺមាន ៩១,៥ ភាគរយ ។ នៅក្នុងសកលលោក ភាគរយនៃយុវជនអាយុចន្លោះពី ១៥ ទៅ ២៤ឆ្នាំ ដែលកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតគឺ ៧០,៦ ភាគរយ។

ក្រុមប្រជាពលរដ្ឋដែលប្រើប្រាស់អ៊ីនធឺណែតនៅកម្ពុជា គឺមានអាយុកាន់តែតិចទៅៗ ដោយក្នុងចំណោមកុមារអាយុ ១៥ឆ្នាំទាំងអស់គឺមាន ៤,៥ ភាគរយកំពុងប្រើប្រាស់អ៊ីនធឺណែត។ ខណៈពេលដែលសិស្សមានអាយុកាន់តែច្រើនកាន់តែងាយប្រឈមនឹងការសម្លុតគំរាមតាមប្រព័ន្ធអ៊ីនធឺណែត បើធៀបនឹងសិស្សដែលមានអាយុតិចជាង ហើយកុមារគឺជាក្រុមដែលងាយរងគ្រោះពីព័ត៌មានគ្រោះថ្នាក់ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ និងការសម្លុតគំរាមតាមប្រព័ន្ធអ៊ីនធឺណែតផងដែរ។

ប្រភពដដែលបានបន្តថា ការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណែត អាចបង្កឱ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ហើយវាអាចកើតលើមនុស្សជាច្រើននាក់។ សកម្មភាព និងព័ត៌មានបៀតបៀនទាំងនោះនៅតែមានវត្តមាននៅលើប្រព័ន្ធអនឡាញ ដោយគ្មានពេលកំណត់ ពោលគឺវា «នៅតែតាមធ្វើបាប» ជនរងគ្រោះតាមប្រព័ន្ធអនឡាញពេញមួយជីវិត។ ការរករឿងឈ្លោះនៅខាងក្រៅ និងការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណែត គឺជាសកម្មភាពអាក្រក់ពីរបំពេញគ្នាទៅវិញទៅមក ដោយបង្កើតជាវិយាបថបង្កការឈឺចាប់ និងខូចខាតតគ្នាពីមួយទៅមួយមិនចេះចប់។ ជនរងគ្រោះដោយសារការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណែត អាចរងផលប៉ះពាល់ដោយទំនងជាឈានទៅប្រើប្រាស់គឿងស្រវឹង គ្រឿងញៀន និងគេចមិនចូលរៀនជាងសិស្សដទៃទៀត។ ពួកគេក៏ច្រើនតែទទួលបានពិន្ទុទាប និងផ្តល់តម្លៃឱ្យខ្លួនឯងទាប ក៏ដូចជាជួបប្រទះនឹងបញ្ហាសុខភាពជាច្រើន។ ក្នុងស្ថានភាពធ្ងន់ធ្ងរ ការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណែត អាចនាំឱ្យមានការធ្វើអត្តឃាតក៏មាន។

លោកស្រី ណាតាសា ផាឱសុន នាយិកាស្តីទីយូនីសេហ្វប្រចាំប្រទេសកម្ពុជាបានបន្តទៀតថា ៣០ឆ្នាំ ក្រោយការអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងការបង្កើតប្រព័ន្ធអ៊ីនធឺណែត គឺដល់ពេលដែលរដ្ឋាភិបាល គ្រួសារ ស្ថាប័នសិក្សាស្រាវជ្រាវ និងជាពិសេសវិស័យឯកជនគិតពិចារណាពីកុមារ និងយុវជន ដោយចាត់ទុកពួកគេជាស្នូលនៃគោលនយោបាយឌីជីថល។ តាមរយៈការការពារពួកគេពីហេតុការណ៍អាក្រក់បំផុតដែលកើតចេញពីការប្រើប្រាស់អ៊ីនធឺណែត និងពង្រីកការប្រើប្រាស់អ៊ីនធឺណែតរបស់ពួកគេ យើងម្នាក់ៗអាចជួយឱ្យមានតុល្យភាព ដើម្បីឧត្តមប្រយោជន៍របស់កុមារ និងយុវជន។

ក្រៅពីអ្នកជំនាញការ រឿងរ៉ាវអវិជ្ជមានតាមប្រព័ន្ធអ៊ីនធឺណែតនេះ ក៏ត្រូវបានប្រជាពលរដ្ឋសាមញ្ញនានា បានមើលឃើញផងដែរ ។

លោក ជា ចេងតារិទ្ធ ជាមន្ត្រីរាជការមួយរូប បានថ្លែងថា មិនចាំបាច់ទៅដល់អ្នកជំនាញការនោះទេ សូម្បីតែលោក និងមិត្តភក្តិរបស់លោកក៏មើលឃើញហានិភ័យនៃការប្រើប្រាស់អ៊ីនធឺណែតនេះដែរ ដូច្នេះហើយ បានជាលោកកំពុងតែព្យាយាមតម្រែតម្រង់កូនៗរបស់លោក។

លោកបានបញ្ជាក់ថា៖ «យើងអ្នកចេះ អ្នកដឹង គឺដឹងអំពីគុណសម្បត្តិ និងគុណវិបត្តិ ប៉ុន្តែកូនៗ ដែលជាយុវវ័យអាចអត់ដឹងទេ ចឹងហើយបានជាពេលទំនេរ ខ្ញុំតែងតែណែនាំ ខ្លះៗឲ្យគេរៀនចេះវិភាគរៀនចេះគិត»៕



រូបភាពតំណាង

# ដំរីព្រៃកម្ពុជាកើនឡើង បន្ទាប់ពីមាន ការយកចិត្តទុកដាក់អភិរក្ស

*ដោយ: ឌី ដេន*



*ដំរីដែលស្ថិតក្រោមការមើលថែរក្សាក្នុងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ។ រូបភាព៖ ឌីដេន*

ក្រសួងបរិស្ថានកំពុងតែរៀបចំផែនការ ១០ឆ្នាំដើម្បីអភិរក្សសត្វដំរី ដែលមាននៅក្នុងប្រទេសកម្ពុជាឱ្យបានគង់វង្ស ខណៈដែលចំនួនសត្វដំរីមានការកើនឡើង និងកំពុងរស់នៅក្នុងព្រៃនានារបស់កម្ពុជា។ សត្វដំរីទាំងអស់ កំពុងត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ពីសំណាក់ ក្រសួងបរិស្ថានក្នុងការងារអភិរក្ស។

លោក នេត្រ ភក្ត្រា អ្នកនាំពាក្យក្រសួងបរិស្ថានបាននិយាយថា ការអភិរក្សសត្វដំរី ឲ្យបានគង់វង្សនៅប្រទេសកម្ពុជា អ្វីដែលចាំបាច់ត្រូវធ្វើ គឺ ការខិតខំប្រឹងប្រែង ធ្វើការអភិរក្សធនធានធម្មជាតិ ព្រៃឈើដែលជាជម្រកដីធំមួយសម្រាប់សត្វដំរី។

លោកបានបន្តថ្លែងថា៖ «យើងបាន និងកំពុងរៀបចំនូវអ្វីដែលហៅថា ច្រករបៀងអភិរក្សជីវៈចម្រុះ ដែលច្រករបៀងនេះយើងរក្សាទុកនូវកន្លែងសម្រាប់ធ្វើដំណើរចេញចូលពីតំបន់មួយទៅតំបន់មួយរបស់សត្វដំរី។ ការបង្កើតច្រករបៀងជីវចម្រុះ គឺបានផ្តល់ផលប្រយោជន៍ ដល់ការបំលាស់ទីរបស់សត្វដំរីព្រៃរបស់កម្ពុជា អាចធ្វើដំណើរឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយ ក្នុងដែនជម្រកសត្វព្រៃ ហើយវាក៏បានបង្កលក្ខណៈល្អប្រសើរ ដល់ការរស់នៅ និងការបន្តពូជរបស់ដំរីព្រៃផងដែរ"។

អ្នកនាំពាក្យរូបនេះបានឲ្យដឹងបន្ថែមថា តាមការប៉ាន់ប្រមាណសត្វដំរី នៅកម្ពុជា មានប្រមាណជា៥០០ក្បាល ដែលកំពុងរស់នៅក្នុងព្រៃនានារបស់កម្ពុជា ដូចជា តំបន់ជួរភ្នំក្រវាញ តំបន់ព្រៃឡង់ ឧទ្យានជាតិគិរីរម្យ ភូមិភាគប៉ែកឦសាន ខេត្តរតនគិរី មណ្ឌលគិរី និងខេត្តស្ទឹងត្រែងជាដើម។

ការបង្កើតច្រករបៀងជីវៈចម្រុះនេះ គឺផ្តល់ផលប្រយោជន៍ដល់សត្វព្រៃ និងដំរីព្រៃ ពោលគឺរក្សាទុកកន្លែងធ្វើដំណើររបស់សត្វព្រៃពីតំបន់មួយទៅតំបន់មួយ និងផ្តល់ផលប្រយោជន៍ដល់ការឆ្លងកាត់របស់សត្វដំរីព្រៃ ពីតំបន់មួយទៅតំបន់មួយ ក្នុងដែនជម្រកសត្វ។

លោក នេត្រ ភក្ត្រា បានបញ្ជាក់ថា៖ «យើងខិតខំធ្វើយ៉ាងណាការពារឲ្យបានជម្រកដីធំ ក៏ដូចជាព្រៃឈើសម្រាប់ផលប្រយោជន៍របស់សត្វព្រៃពិសេសសត្វដំរីរបស់ប្រទេសកម្ពុជា»។

ផ្ទៃដីដែលស្ថិតនៅក្នុងការអភិរក្សរបស់ក្រសួងបរិស្ថានមានប្រមាណ ៧,៥លានហិកតា នៅទូទាំងប្រទេសកម្ពុជាមានប្រមាណ៤១% នៃផ្ទៃដីសរុបរបស់កម្ពុជា។

មន្ត្រីដដែលរូបនេះបានបន្តថា បច្ចុប្បន្នធនធានធម្មជាតិនៅកម្ពុជាត្រូវបានការពារយ៉ាងល្អ ហើយអាជ្ញាធរបានបង្ក្រាបជាប្រចាំលើការរុករានផ្សេងៗ ទប់ស្កាត់ការកាប់ឈើ និង ការបរបាញ់សត្វដោយខុសច្បាប់ជាដើម។

គួររំឭកផងដែរថា កាលពីចុងខែកុម្ភៈកន្លងមកនេះ មន្ត្រីឧទ្យានុរក្សនៃដែនជម្រកសត្វព្រៃដែនសីម៉ា បានប្រទះឃើញសត្វដំរីឈ្មោលដែលមានវ័យចំណាស់មួយក្បាលបានស្លាប់នៅក្នុងចម្ការចន្ទីរបស់ប្រជាពលរដ្ឋ ស្ថិតនៅស្រុកកែវសីម៉ា ភូមិសាស្ត្រខេត្តមណ្ឌលគិរី។

តាមការសន្និដ្ឋាន ដំរីនេះត្រូវបានខ្មាន់កាំភ្លើងបាញ់ស្លាប់ប្រមាណជា ១០ថ្ងៃមកហើយមុនពេលសាកសពវាត្រូវបានពើបប្រទះ។

លោក នេត្រ ភក្ត្រា អ្នកនាំពាក្យនៃក្រសួងបរិស្ថានបានប្រាប់ឲ្យដឹងថា ដំរីព្រៃនេះមានកម្ពស់ ២,៧០ ម៉ែត្រ ប្រវែង ៤,៥០ ម៉ែត្រ ទទឹង ១,៥០ ម៉ែត្រ។ ដំរីនេះត្រូវបានគេបាញ់សម្លាប់ដោយគ្រាប់កាំភ្លើងថ្លៃ សង្ស័យបង្កប់ជាតិពុលក្នុងនោះ និងមានស្នាមផ្លះមួយកន្លែងនៅប្រមាណមួយចំអាមពីភ្នែកស្តាំ ដែលមន្ត្រីជំនាញសន្និដ្ឋានថាជាស្នាមផ្លះដោយគ្រាប់កាំភ្លើងរបស់ជនទុច្ចរិតបានបាញ់។

លោកបានបន្តថា សាកសពដំរីនេះត្រូវមន្ត្រីនៃមន្ទីរបរិស្ថានខេត្តមណ្ឌលគិរីយកទៅកប់នៅកន្លែងមានសុវត្ថិភាព ដើម្បីរក្សាទុក គ្រោងឆ្អឹង សម្រាប់ជាប្រយោជន៍ធ្វើការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រលើជីវិៈចម្រុះទាក់ទងនឹងជីវិតសត្វដំរីព្រៃនៅប្រទេសកម្ពុជា។

លោកភក្ត្រាបានថ្លែងថា៖ «យើងសូមថ្កោលទោសចំពោះការបាញ់សម្លាប់សត្វដំរីដែលជាសត្វកម្រនៅប្រទេសកម្ពុជា ហើយសមត្ថកិច្ចបាននិងកំពុងធ្វើការស៊ើបអង្កេតដើម្បីឈានទៅរកមុខរកជនល្មើសដែលបាញ់សម្លាប់សត្វដំរីនេះ។ ក្រសួងបរិស្ថានក៏សូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ចូលរួមការពារ និងអភិរក្សសត្វដំរីនៅកម្ពុជាឲ្យបានគង់វង្ស និងចៀសវាងការបរបាញ់សត្វដំរី»។

អ្នកនាំពាក្យរូបនេះបានបន្ថែមថា រយៈពេល ៣ ឆ្នាំចុងក្រោយនេះ មានសត្វដំរីព្រៃចំនួន ៣ ក្បាលបានស្លាប់នៅក្នុងព្រៃនៃខេត្តមណ្ឌលគិរី ដោយសារតែការបាញ់សម្លាប់ និងស្លាប់ដោយវ័យចាស់ជរា។

នៅក្នុងតំបន់ការពារធម្មជាតិក្នុងខេត្តមណ្ឌលគិរី ត្រូវបានគេសន្និដ្ឋានថាមានសត្វដំរីព្រៃរស់នៅប្រមាណពី ១២០ ទៅ ១៧០ ក្បាល។

សព្វថ្ងៃនេះ ក្រសួងបរិស្ថានបាន និងកំពុងការពារ និងអភិរក្សប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះមានផ្ទៃដីទំហំប្រមាណ ៧,៥លានហិកតា ( ៤១%នៃផ្ទៃដីសរុបប្រទេសកម្ពុជា )៕



*សត្វដំរីឈ្មោលដែលគេលួចបាញ់សម្លាប់។ រូបភាព៖ សហការី*



*លោក នេត្រ ភក្ត្រា អ្នកនាំពាក្យក្រសួងបរិស្ថាន។ រូបភាព៖ ហ្វេសប៊ុក*

# គុណភាពខ្យល់នៅកម្ពុជាប្រែប្រួលនៅក្នុងកម្រិតមួយ
# មិនលើសពីស្តង់ដានៃការបំពុល



*ផ្អែកតាមលទ្ធផលត្រួតពិនិត្យរបស់ក្រសួងបរិស្ថានបង្ហាញថា គុណភាពខ្យល់នៅក្នុងរាជធានីភ្នំពេញមានកម្រិតល្អប្រសើរ។ រូបភាព៖ ឌីដេន*

*ដោយ៖ អរិយបុត្រ*

ក្រសួងបរិស្ថានបានអះអាងថា គុណភាពខ្យល់នៅក្នុងប្រទេសកម្ពុជា គឺមានការប្រែប្រួល ប៉ុន្តែកម្រិតនៃការបំពុលនៅមិនទាន់មានការប្រែប្រួលឈានទៅលើសកម្រិតអវិជ្ជមានចំពោះសុខភាពនៅឡើយទេ។

ក្រសួងបរិស្ថានបានអះអាងថា៖ «ជូនដំណឹងដល់សាធារណជនអំពីស្ថានភាពគុណភាពខ្យល់នៅក្នុងរាជធានីភ្នំពេញថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៩ ផ្អែកតាមលទ្ធផលត្រួតពិនិត្យបង្ហាញថា គុណភាពខ្យល់នៅក្នុងរាជធានីភ្នំពេញមានកម្រិតល្អប្រសើរ»។

ប្រភពដដែលបានប្រកាសថា កម្រិតភាគល្អិតនិចល PM2.5 នៅក្នុងខ្យល់មានជាមធ្យម២២, ៩៥ មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប ធៀបទៅនឹងកម្រិតស្តង់ដារ PM 2.5 គឺ ៥០ មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប ក្នុងរយៈពេល ២៤ ម៉ោង នៃការអង្កេតនៅក្នុងរាជធានីភ្នំពេញ នៃថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៩ ។

ប្រភពដដែលបានអះអាងថា កម្រិតភាគល្អិតនិចល PM2.5 នៅក្នុងខ្យល់នេះ គឺមានការប្រែប្រួលដោយកាលពីថ្ងៃ ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៩ គឺវាបានធ្លាក់មកនៅត្រឹមតែ ១៩,១៨ មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប។ ខណៈដែលនៅថ្ងៃទី ០៦ ខែ ឆ្នាំដដែល គឺវានៅក្នុងកម្រិត ២១,៤០ មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប ហើយនៅក្នុងថ្ងៃទី ០៤ ខែឆ្នាំដដែលគឺ នៅក្នុងកម្រិត ២២,៩២ មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប។

ដោយឡែកតាមប្រភពក្រសួងបរិស្ថានដដែលបានឲ្យដឹងថា នៅក្នុងចន្លោះពីថ្ងៃទី ២៧ ខែ មករា ដល់ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៩ នេះ កម្រិតភាគល្អិតនិចល PM2.5 នៅក្នុងខ្យល់មានជាមធ្យមគឺរហូតដល់ ៣៥,១៣ មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប។

លោក នេត ភក្ត្រា អ្នកនាំពាក្យនិងជារដ្ឋលេខាធិការក្រសួងបរិស្ថាន បានថ្លែងថា គុណភាពខ្យល់នៅក្នុងប្រទេស ជាពិសេសគឺនៅរាជធានីភ្នំពេញ គឺល្អប្រសើរ ហើយបរិយាកាសគឺនៅតែប្រក្រតី ដូច្នេះ មិនមានអ្វីដែលគួរឲ្យបារម្ភចំពោះវានៅឡើយទេ ។

លោកបានបន្តទៀតថា មកដល់ពេលនេះ ក្រុមការងារ និងអ្នកជំនាញការរបស់ក្រសួងបរិស្ថាន គឺបានបន្តតាមដានគុណភាព ហើយក្រសួងនឹងផ្តល់ជូនព័ត៌មានអំពីគុណភាពខ្យល់នេះជាបន្តបន្ទាប់។ សូមកុំមានការព្រួយបារម្ភ ។



*រូបភាពតំណាង*

> ***"ឥឡូវដូចជាមិនដែលបានឃើញមេឃពណ៌ផ្ទៃមេឃស្រឡះល្អសោះ ឃើញតែស្រអាប់ និង សំបូរអព្ទ ចឹងហើយបានជាបារម្ភ ប៉ុន្តែសុខភាពខ្ញុំ និង គ្រួសារដូចជាមិនអីដែរ គ្រាន់តែផ្តាស់សាយបន្តិចបន្តួច"***

លោក ស៊ុំ ចាន់តុលា ជាប្រជាពលរដ្ឋមួយរូបបានថ្លែងថា លោកចេះតែបារម្ភហើយ ពីព្រោះមើលព័ត៌មានអន្តរជាតិទៅ ឃើញនៅបាងកក គឺកម្រិតបំពុលនោះ គឺឈានទៅដល់គ្រោះថ្នាក់ ដូច្នេះខ្លាច វារសាត់មកដល់កម្ពុជា។

លោកបានបញ្ជាក់ថា៖ ចេះតែខ្លាចហើយ ព្រោះនៅបាងកក ព័ត៌មានចេះតែមានជាបន្តបន្ទាប់ ដូច្នេះ ថ្ងៃណាមួយខ្លាចវារសាត់មកដល់កម្ពុជា ពីព្រោះខ្យល់វាគ្មានព្រំដែន ហើយក៏មិនត្រូវទិដ្ឋាការអី ដូចមនុស្សដែរ តែវារសាត់មក វាចេះតែធ្វើដំណើរពាសវាលពាសកាលហើយ។

លោកស្រីជាតិ សម្ផស្សជាស្ត្រីមេផ្ទះមួយរូប ក៏បានសំដែងការព្រួយបារម្ភនេះដែរ ដោយសារតែលោកស្រីឃើញមេឃដូចជាមិនស្រឡះសោះ។

លោកស្រីបានបញ្ជាក់ថា៖ «ឥឡូវដូចជាមិនដែលបានឃើញមេឃពណ៌ផ្ទៃមេឃស្រឡះល្អសោះ ឃើញតែស្រអាប់ និង សំបូរអព្ទ ចឹងហើយបានជាបារម្ភ ប៉ុន្តែសុខភាពខ្ញុំ និង គ្រួសារដូចជាមិនអីដែរ គ្រាន់តែ ផ្តាស់សាយបន្តិចបន្តួច»។

យោងតាមសន្ទស្សន៍នៃគុណភាពខ្យល់ ( Air Quality Index ) កម្រិតភាគល្អិតនិចល PM2.5 នៅក្នុងខ្យល់មានជាមធ្យម គឺត្រូវនៅចន្លោះពី 0-៥0 មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប។ អត្រាបំពុលនៅក្នុងចន្លោះនេះ គឺមិនមានផលប៉ះពាល់អ្វីដល់សុខភាពនៅឡើយទេ ប៉ុន្តែវានឹងចាប់ផ្តើមមានហានិភ័យ បន្តិច ប្រសិនបើវាឈានដល់កម្រិត ពី ៥១-១០០មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប ។ គុណភាពខ្យល់ដែលមានកម្រិតបំពុលបែបនេះ គឺអាចបង្កផលប៉ះពាល់ដល់សុខភាព ហើយមនុស្សដែលអាលែកហ្ស៊ី គឺចាប់ផ្តើមមានបញ្ហា។ហើយ បើកម្រិតបំពុលនេះ វាមានពី ១០១ -១៥០ មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប នោះ មនុស្សអាចនឹងប្រឈមមុខនឹងរោគសញ្ញាសុខភាពផ្អែកផ្លូវដង្ហើម ។ ហើយនៅក្នុងករណី ដែលការបំពុលនេះកើនឡើងពីចន្លោះ ១៥១ - ២០០ មីក្រូក្រាមនៅក្នុងមួយម៉ែត្រគូប នោះកម្រិតបំពុលគឺចាប់ផ្តើមមានគ្រោះថ្នាក់ដល់មនុស្ស គឺមនុស្សចាប់ផ្តើមធ្លាក់ខ្លួនឈឺតែម្តង៕

# ក្រសួងថា កម្ពុជាអាចនាំចេញបន្លែខ្លះ! ប៉ុ
# មិនដឹងព្រោះបរិមាណគាត់ដាំនៅម

## បើទោះបីជាការនាំចេញបន្លែវាមិនមានបរិមាណច្រើនក៏ដោយ ប៉ុន្តែក្រសួងកសិកម្ម រុក្ខាប្រ
## អះអាងនៅក្នុងរបាយការណ៍មួយថា កម្ពុជាកាលពីឆ្នាំទៅ អាចនាំចេញបន្លែខ្លះទៅសហគ

របាយការណ៍ស្ដីពីការនាំចេញបន្លែទៅកាន់សហគមន៍អឺរ៉ុបនេះ គឺចេញនៅពេលដែលទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរៀបចំវេទិកាសាធារណៈមួយស្ដីពីវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមអធិបតីភាពលោករដ្ឋមន្ត្រី វេង សាខុន កាលពីចុងខែ កុម្ភៈកន្លងទៅ ថ្មីៗនេះ។

នៅក្នុងវេទិកាដែលមានការចូលរួមពីតំណាងក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមហ៊ុនឯកជន និង ដៃគូអភិវឌ្ឍ ប្រមាណជា ៤០០នាក់ ដែលមានគោលបំណងដើម្បីបង្កើតឱកាសឲ្យ ពិភាក្សា ផ្លាស់ប្ដូរ ឬចែករំលែកបទពិសោធន៍ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាព កាលានុវត្តភាព បញ្ហាប្រឈមនានាដែលបាន និងកំពុងជួបប្រទះក្នុងការអនុវត្តការងារវិស័យកសិកម្ម នោះ លោក វេង សាខុន បានមានប្រសាសន៍ថា ថ្មីៗនេះកម្ពុជាបាននាំចេញបន្លែស្រស់ទៅកាន់ទីផ្សារសហភាពអឺរ៉ុបបានជាង ៣៣តោន ដែលនេះជាមោទនភាពនៃការសម្រេចបាននូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារបស់ក្រសួងក្នុងការជំរុញកំណើនផលិតកម្មកសិកម្មក្នុងស្រុក ជំរុញការនាំចេញ លើកកម្ពស់សក្ដានុពលក្នុងការប្រកួតប្រជែងទីផ្សារទាំងក្នុង និងក្រៅប្រទេស។

លោករដ្ឋមន្ត្រីមិនបានបញ្ជាក់លំអិតថា តើបន្លែដែលកម្ពុជានាំចេញនោះជាបន្លែអ្វីខ្លះនោះទេ ខណៈអ្នកនាំពាក្យក្រសួងមិនអាចទំនាក់ទំនងបាន នៅពេលអ្នកនាំសារព្យាយាមសុំព័ត៌មានលំអិតអំពី ប្រភេទបន្លែដែលកម្ពុជាអាចនាំចេញទៅកាន់សហភាពអឺរ៉ុបនេះ។

តាមព័ត៌មានដែលលោក វេង សាខុន បានឲ្យដឹងនៅក្នុងវេទិកាខាងលើនោះ គឺថា ក្រៅពីបន្លែចេញ ផលិតផលកសិកម្មថ្មីៗដែលកម្ពុជាអាចនាំចេញបានទៅកាន់ទីផ្សារអន្តរជាតិកាលពីឆ្នាំទៅ គឺមាន ដូចជា ចេកអំបូងលឿងប្រមាណជាង១ម៉ឺនតោន និង ស្វាយកែវរមៀតប្រមាណជាង ១ម៉ឺនតោនផងដែរ។

ជុំវិញតួរលេខនៃការនាំចេញបន្លែនេះ កសិករដែលកំពុងតែប្រកបរបរដាំបន្លែមួយចំនួននៅខេត្តកណ្ដាល គឺមិនបានដឹងទេ ដោយសារតែបរិមាណផលិតកម្មបន្លែដែលពួកគាត់អាចដាំ និងបានដាំនៅក្នុងពេលបច្ចុប្បន្ននេះ គឺនៅមានកម្រិត ។

លោកស្រី ភោគ ផល្លា ជាកសិករដែលប្រកបរបរដាំដំណាំនៅតាមបណ្ដោយមាត់ទន្លេមេគង្គ ម្តុំស្រុកមុខកំពូល ខេត្តកណ្ដាល ដែលកំពុងតែដឹកបន្លែបម្រុងនឹងនាំមកលក់នៅរាជធានីភ្នំពេញបានឲ្យដឹងថា ពពួកបន្លែដែលពួកគាត់អាចដាំបាននាពេលបច្ចុប្បន្ននេះ គឺមានដូចជា ផ្លែប៉េងប៉ោះ ម្ទេសទាំងហ៊ឺ និង ប្រភេទបន្លែដែលគេយកទៅឆាបាន ពពួកបន្លែស្លឹកដូចជា សាឡាត់ ស្ពៃ ជាដើម ប៉ុន្តែជារួម គឺអាចដាំបានតែនៅពេលដែលទឹកស្រកប៉ុណ្ណោះ ពោលគឺប្រមាណជា ៥ ទៅ ៦ ខែ។

លោកស្រីបានបញ្ជាក់ថា៖ «ដាំម៉េចបានរហូត តែទឹកឡើងលិចអស់ហើយ គ្មានដីដាំកើតទេ ហើយពួកខ្ញុំ គឺមានតែដេកស៊ីប៉ុណ្ណោះ មិនដឹងរកអី»។

លោកស្រីបានបន្តថា ដោយឡែកទីផ្សារបន្លែរបស់លោកស្រី គឺគ្មានទីណាក្រៅពីផ្សារនៅក្នុងរាជធានីនោះទេ។ លោកស្រីបានបញ្ជាក់ថា ទាំងបន្លែលោកស្រីដាំខ្លួនឯងបានខ្លះ ទិញពីគេពីឯងបានខ្លះ គឺសម្រាប់តែ ដឹកមួយម៉ូតូៗ យកមកបោះឲ្យម៉ូយនៅផ្សារ ចាស់ ផ្សារកណ្ដាល ផ្សារដើមគរ ហើយ ជួនកាលទៅ គឺអង្គុយលក់ខ្លួនឯង នៅផ្សារនេះផ្សារនោះចឹងទៅ នៅពេលបន្លែវាជន ហើយ តម្លៃវាថោក បោះឲ្យគេមិនចំណេញ។

អ្នកដឹកបន្លែមួយរូបមកពីស្រុកស្អាង ដែលគេដឹងថា គឺជាប្រភពបន្លែដ៏ចំបងសម្រាប់ផ្គត់ផ្គង់ទីផ្សារ នៅរាជធានីភ្នំពេញ ឈ្មោះ សុខ សម្បត្តិ បានអះអាងថា លោកមិនដឹងជាមានបន្លែឯណានាំចេញទៅក្រៅបានទេ ពីព្រោះរាល់ថ្ងៃនេះ គឺរកបន្លែដឹកឲ្យម៉ូយមិនចង់បានផង។

លោកបានបន្តទៀតថា នៅខែនេះជាខែទឹកស្រក អីចឹង គឺសំបូរបន្លែ។ នៅតាមទីផ្សារក្នុងពេលដែលមានបន្លែជន់មកច្រើនបែបនេះ តម្លៃវាងថោកបន្តិច ហើយក៏វាច្រើនដែរ ពីព្រោះ



*កម្ពុជាត្រូវការបន្លែជាមធ្យមប្រមាណជា ៥៤០ តោន នៅក្នុងមួយថ្ងៃ។ រូបភាព៖ សម្បត្តិ*

> ***"ខែនេះ ត្រូវការបន្លែ អី យើងអាចទៅ ប្រមូលពីកសិករ នៅម៉ុស្អាង មុខកំពូល អីបាន តែបើខែ ទឹកលិចវិញ គឺភាគ ច្រើនយកពីខាងវៀតណាម មកវិញ"***

ទីណា ក៏អាចដាំបាន ឲ្យតែមានទឹក ប៉ុន្តែបើនៅខែវស្សាទឹកលិចវិញ គឺបន្លែរាងខ្សត់ ដឹកឲ្យម៉ូយសឹងតែមិនទាន់។

លោកបានបន្តថា សព្វថ្ងៃនេះ បន្លែដែលលោកដឹករាល់ថ្ងៃ គឺមានតាំងពីឆៃថាវ ខាត់ណាស្ពៃក្តោប ស្លឹកគ្រៃ ខ្ទឹម ស្ពៃខៀវ ស្ពៃចង្កឹះ ផ្កាខាត់ណា ជី ម្អម ត្រសក់ ម្រះ... អីហ្នឹង ។ ល។ ហើយអតិថិជនដែលលោកដឹក ឲ្យ នោះ គឺនៅតាមផ្សារដើមគរ និង តាមហាងលក់ស៊ុប និងភោជនីយដ្ឋានមួយចំនួន ប៉ុន្តែគឺមិនដែលបានដឹកឲ្យអ្នកនាំចេញណាទេ។

លោកបានបញ្ជាក់ថា៖ «ខែនេះ ត្រូវការបន្លែអី យើងអាចទៅប្រមូលពីកសិករនៅម៉ុស្អាង មុខកំពូល អីបាន តែបើខែ ទឹកលិចវិញ គឺភាគច្រើនយកពីខាងវៀតណាម មកវិញ»។

លោកបានបន្តទៀតថា ប្រភេទបន្លែខ្លះ ជា

# ន្តកសិករថៃ នកម្រិត!

## មាញ់ និងនេសាទបាន មន៍អឺរ៉ុប។



កសិករកំពុងស្រោចដំណាំរបស់ខ្លួន។ រូបភាព៖ សម្បត្តិ



កសិករកំពុងប្រមូលផលប៉េងប៉ោះក្នុងចំការ។ រូបភាព៖ ក្រសួងកសិកម្ម

ប្រភេទបន្លែស្លឹក ដូចជាស្ពៃ និងបន្លែសម្រាប់ស៊ុប អី គឺយើងអាចទៅរកត្រឹមស្អាងអីបាន នៅពេលដែលខ្សត់ ប៉ុន្តែបន្លែខ្លះ គឺគ្មានតែម្តង នៅពេលទឹកលិច។

ប្រភេទបន្លែដែលមាននៅក្នុងរបាយការណ៍នាំចេញទៅសហភាពអឺរ៉ុបរបស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និង នេសាទនេះ អ្នកលក់បន្លែសរីរាង្គនៅហាងលក់បន្លែសរីរាង្គមួយរូបបានអះអាងថា ប្រភេទបន្លែដែលអាចនាំចេញទៅកាន់ទីផ្សារនោះបាន ប្រហែលមានតែប្រភេទបន្លែសរីរាង្គទេ ប៉ុន្តែលោកក៏មិនអាចដឹងច្បាស់ដែរ ពីព្រោះទីផ្សារបន្លែសរីរាង្គនៅក្នុងស្រុកក៏ដាច់ និង ពេញនិយម ហើយពេលខ្លះក៏ជួបនឹងបញ្ហាកង្វះបន្លែដែរ។

លោកបានអះអាងនៅក្នុងលក្ខខណ្ឌមិនបញ្ចេញអត្តសញ្ញាណថា មូលហេតុដែលលោកហ៊ានសន្និដ្ឋានបែបនោះ គឺដោយសារតែ អឺរ៉ុបស្តង់ដាគេខ្ពស់ណាស់ ហើយការត្រួតពិនិត្យក៏ខ្ពស់ដែរ ដូច្នេះ មានតែពពួកបន្លែសរីរាង្គទេ ដោយសារវាធម្មជាតិ ហើយមានស្តង់ដានៃការដាំដុះត្រឹមត្រូវ ពិសេសគឺអត់មានប្រើសារធាតុគីមី ដែលអាចនឹងប៉ះពាល់ដល់សុខភាព ប៉ុន្តែវាក៏ទាមទារនូវការថែទាំនោះ ខ្ពស់ដែរ។

លោកបានបន្តទៀតថា ក្រៅពីបន្លែសរីរាង្គនេះចេញ លោកមើលមិនឃើញថា មានបន្លែអ្វីផ្សេងទៀតនោះទេ ប៉ុន្តែបើនាំចេញទៅប្រទេសជិតខាង ពិសេសគឺ ថៃ អាចមានជាប្រភេទពពួកបន្លែដែលដុះនៅក្នុងព្រៃ ដែលគេប្រើពាក្យថា អនុផលព្រៃឈើ។ លោកបានបន្តថា បន្លែបែបនេះ គឺអ្នកស្រុកនៅស្រុកយើង គឺ បានកំពុងតែប្រកបរបរទទួលទានរាល់ថ្ងៃ ដោយពួកគេទៅបេះនៅក្នុងព្រៃ ហើយ ប្រមូលយកមកលក់នៅតាមផ្សារនានាតាមព្រំដែន ឬ បោះឲ្យគេយកទៅលក់បន្តនៅក្នុងប្រទេសជិតខាង។ តែបើនិយាយអំពីការនាំចេញឲ្យធំដុំ មានការកត់ត្រា ពិតប្រាកដ គឺដូចជាគ្មានទេ។

តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ កាលពីឆ្នាំ២០១៨ កន្លងទៅនេះ កម្ពុជាត្រូវការបន្លែជាមធ្យមប្រមាណជា ៥៤០ តោន នៅក្នុងមួយថ្ងៃ ប៉ុន្តែកសិករកម្ពុជាអាចមានលទ្ធភាពដាំបន្លែសម្រាប់យកមកផ្គត់ផ្គង់ទីផ្សារ និងតម្រូវការហូបចុករបស់ប្រជាពលរដ្ឋបានត្រឹមតែប្រមាណជា ៤០០ តោន ប៉ុណ្ណោះ នៅសល់ប៉ុន្មានគឺត្រូវការនាំចូល។ម្យ៉ាងវិញទៀតកម្លាំងផលិតកម្មនេះ គឺក៏ពឹងផ្អែកតាមរដូវថែមទៀត។

ជុំវិញបញ្ហាបន្លែនេះ លោក វេង សាខុន បានថ្លែងថា ក្រសួងកំពុងតែយកចិត្តទុកដាក់នៅក្នុងការលើកទឹកចិត្តដើម្បីជំរុញកសិករឲ្យដាំបន្លែ និងរិះរកវិធីសាស្ត្រដើម្បីជួយបង្កើនផលិតកម្មបន្លែ ក៏ដូចជារៀបចំនូវយុទ្ធសាស្ត្រគ្រប់គ្រងទីផ្សារឲ្យខ្សែរសង្វាក់ផលិតកម្មនោះមាននិរន្តភាព។

លោករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ក្រសួងកំពុងតែខិតខំប្រែក្លាយជាចលកររុញឲ្យវិស័យកសិកម្មវិវឌ្ឍន៍រីកចម្រើនថែមទៀត ឆ្លើយតបតាមកំណើនសេដ្ឋកិច្ច កំណើនប្រជាជន និងទេសចរណ៍ក្នុងស្រុក ជាពិសេសស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនាឆ្នាំ ២០៣០។

លោកបានបន្តថា វិស័យនេះបានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៅឯជនបទ ពិសេសផ្តល់នូវប្រភពស្បៀងអាហារសម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍផ្នែកកសិ-ឧស្សាហកម្ម និងជាប្រភពចំណូលជាតិដ៏សំខាន់ ដែលទទួលបានពីការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងការនាំចេញផលិតផលកសិកម្មចូលទៅក្នុងទីផ្សារជាតិ និងអន្តរជាតិ។

តាមរយៈលោករដ្ឋមន្ត្រីដែលបានថ្លែងនៅក្នុងពិធីផ្សេងៗ នាពេលបច្ចុប្បន្ននេះ គេដឹងថា ក្រសួងកំពុងចាប់ដៃជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងៗ ដើម្បីជំរុញផលិតកម្មអាហារនៅកម្ពុជា ដោយ គម្រោងមួយចំនួន ត្រូវបានដាក់ឲ្យអនុវត្តនៅខេត្តជាច្រើន ដូចជា តាកែវ កណ្តាល ព្រៃវែង កំពង់ស្ពឺ កំពង់ចាម ពោធិសាត់ កំពង់ឆ្នាំង បាត់ដំបង សៀមរាប និង ត្បូងឃ្មុំជាដើម។

គួរបញ្ជាក់ផងដែរថា សព្វថ្ងៃនេះ ផលិតផលកសិកម្មដែលកម្ពុជាអាចមានលទ្ធភាពនាំចេញបានទៅកាន់ទីផ្សារអន្តរជាតិ គឺមានច្រើនមុខដែរ ដូចជា ម្រេចកំពត ស្ករត្នោតសរីរាង្គ ដំឡូងមី ពោតសត្វរស់ ត្រីទឹកសាប និងត្រីសមុទ្រ ... ជាដើម ប៉ុន្តែបរិមាណនៃការនាំចេញផលិតទាំងនោះ គឺនៅមានកម្រិតមិនច្រើន លើកលែងតែ កៅស៊ូ និង អង្ករ ដែលមានចំនួនមធ្យមដែរ បើទោះបីជាមិនច្រើនដូចជាប្រទេសជិតខាង ដែលគេអាចធ្វើបាន៕

# សិប្បកម្មពពុះសណ្តែកខ្មែរ ១០០គីឡូក្រាមក្នុងមួយថ្ងៃ

*ដោយៈ សុផានិត*



*សកម្មភាពផលិតពពុះសណ្តែក។ រូបភាពៈ ស៊ីអេសស៊ី*



*ពពុះសណ្តែក (ហុកគី) ត្រូវបានហាលសម្ងួត។ រូបភាពៈ ស៊ីអេសស៊ី*

ពពុះសណ្តែកត្រូវបានប្រជាពលរដ្ឋទូទៅស្គាល់ថា ជាអាហារក្រៀមមួយប្រភេទដែលគេអាចយកទៅកែច្នៃជាម្ហូបអាហារបានច្រើនប្រភេទ។

ស្ថិតនៅក្នុងចម្ងាយប្រហែលជា ២០គីឡូម៉ែត្រពីរាជធានីភ្នំពេញ ភូមិពុកឫស្សី នៃឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលដែលគេស្គាល់ថាជាតំបន់ផលិតពពុះសណ្តែកដ៏ធំមួយរបស់ប្រទេសកម្ពុជា។ ប្រជាពលរដ្ឋជិតពាក់កណ្តាលនៃភូមិនេះប្រកបរបរផលិតពពុះសណ្តែកលក់។

លោកស្រី ស្រេង សុខមួយ ជាប្រជាពលរដ្ឋម្នាក់ ក្នុងចំណោមប្រជាពលរដ្ឋផ្សេងទៀត ដែលបើកសិប្បកម្មផលិតពពុះសណ្តែក បានប្រកបរបរផលិតពពុះសណ្តែក តពីឪពុកម្តាយអស់រយៈពេលជាង ៣០ឆ្នាំមកហើយ។

លោកស្រី ស្រេង សុខមួយ បានថ្លែងថា មុខរបររកស៊ីតពីកុងម៉ាពីដើមមកតៗដល់កូនចៅតែម្តង សណ្តែកសៀងយកមកហាលកិនបំបែក យកទៅត្រាំលាងឲ្យស្អាត មិនដាក់ថ្នាំ មិនប្រើជាតិគីមីអ្វីនោះទេ។

អ្នកស្រីបញ្ជាក់ថា៖ «យកត្រាំទឹកហើយលាងវាឲ្យស្អាត ពីរបីទឹកអី ទៅ។ គឺលាងឲ្យសណ្តែកសស្អាត ទើបហុកគី ( ពពុះសណ្តែក )ហ្នឹងវាស្អាត។ មិនបាច់ទៅដាក់ថ្នាំអីទេ»។

លោកស្រី ស្រេង សុខមួយ បន្តថា ត្រូវយកសណ្តែកសៀងដែលលាងទឹករួចទៅត្រាំរយៈពេល២ម៉ោង រួចយកទៅដាក់ក្នុងខ្ទះចាក់ទឹកដាំរយៈពេល២៤ម៉ោងទើបរួចរាល់ក្នុងការធ្វើពពុះសណ្តែក។

លោកស្រី ស្រេង សុខមួយ លើកឡើងដែរថា ទោះបីជាផលិតផលបរទេសដែលមានលក្ខណៈប្រហាក់ប្រហែល គឺជាគូប្រជែងមួយក្នុងការចរាចរទំនិញនៅលើទីផ្សារក្តី តែកត្តាសំខាន់គឺប្រជាជននៅតែពេញនិយមផលិតផលក្នុងស្រុក។ ជាក់ស្តែងដោយសារតែជឿជាក់លើគុណភាពនៃការផលិតពពុះសណ្តែកនៅក្នុងស្រុក លោកស្រី អះអាងថា គ្រួសាររបស់គាត់សព្វថ្ងៃបានផ្គត់ផ្គង់ពពុះសណ្តែកក្នុងមួយថ្ងៃបានប្រមាណជាង ១០០គីឡូក្រាម ទៅឲ្យឈ្មួញនៅទីផ្សារធំៗ ចំនួន៣នៅក្នុងរាជធានីភ្នំពេញ។

លោកស្រីបានបន្ថែមថា ពពុះសណ្តែកមួយគីឡូក្រាមមានតម្លៃចាប់ពី ១៧០០០រៀល ទៅ២០០០០។

ម្ចាស់សិប្បកម្មផលិតពពុះសណ្តែករូបនេះចង់បន្ត និងរក្សាមុខរបរជូនតានេះ ព្រោះជាមុខរបរប្រពៃណីតាំងពីដូនតារបស់គាត់។ គោលបំណងសំខាន់របស់គាត់ គឺដើម្បីជួយឲ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានមានការងារធ្វើ ដោយមិនចាំបាច់ចំណាកស្រុក ពិសេសបានជួយទិញកសិផលសណ្តែកសៀងពីកសិករនៅក្នុងមូលដ្ឋានថែមទៀត និងអាចកាត់បន្ថយលំហូរចូលផលិតផលពីក្រៅប្រទេស៕

# បីប្រទេសរួបរួមគ្នាកាត់បន្ថយការនាំចេញកៅស៊ូ



*ដ័រកៅស៊ូក្នុងពេលប្រមូលផល។ រូបភាពៈ ស៊ីអេសស៊ី*

ប្រទេសថៃ ឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី ដែលគេដឹងថា គឺជាប្រទេសដែលនាំចេញកៅស៊ូច្រើនជាងគេ បានប្រកាសថា ពួកគេនឹងកាត់បន្ថយការនាំចេញកៅស៊ូដោយសារតែកៅស៊ូធ្លាក់ថ្លៃ មែនទែននៅលើទីផ្សារអន្តរជាតិ ។

ក្រុមប្រទេសនាំចេញកៅស៊ូទាំងនេះ បានឲ្យដឹងនៅថ្ងៃទី ៦ ខែមីនា ថា ពួកគេនឹងកាត់បន្ថយការនាំចេញចំនួន ២៤០.០០០ តោនក្នុងរយៈពេល ៤ ខែគិតចាប់ពីខែមេសាតទៅ ក្នុងគោលបំណងធ្វើឲ្យកៅស៊ូនៅលើពិភពលោកឡើងថ្លៃឡើងវិញ។

ចំណាត់ការនេះត្រូវបានប្រកាសជាលើកដំបូងនៅចុងខែកុម្ភៈ បន្ទាប់ពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាកៅស៊ូត្រីភាគីអន្តរជាតិ ដែលរួមមានប្រទេសថៃ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី។

ក្រុមប្រទេសនាំចេញកៅស៊ូនេះ បានឲ្យដឹងក្នុងសេចក្តីថ្លែងការណ៍រួមមួយបន្ទាប់ពីកិច្ចប្រជុំនៅទីក្រុងបាងកកកាលពីសប្តាហ៍មុនដើម្បីបង្កើយសេចក្តីលម្អិតថា ការកាត់បន្ថយការនាំចេញកៅស៊ូនឹងចាប់ផ្តើមនៅខែមេសា និងមានរយៈពេល ៤ ខែ។

ក្រុមប្រទេសទាំងបីនេះបានឲ្យដឹងក្នុងសេចក្តីថ្លែងការណ៍មួយថា «នៅក្រោមការអនុវត្តគម្រោង ប្រទេសទាំងបីបានយល់ព្រមកាត់បន្ថយការនាំចេញកៅស៊ូធម្មជាតិមានចំនួន ២៤០.០០០ តោន»។

ប្រទេសទាំងបីរ៉ាប់រងប្រហែល ៧០ ភាគរយនៃផលិតកម្មកៅស៊ូធម្មជាតិរបស់ពិភពលោក។

សព្វថ្ងៃនេះក្រៅពីប្រទេសទាំងបីនេះ ប្រទេសមួយចំនួនទៀតនៅអាស៊ីអាគ្នេយ៍ដូចជា វៀតណាម កម្ពុជា និងឡាវ ជាដើម កំពុងតែខិតខំពង្រីកផ្ទៃដីដាំកៅស៊ូ។

សម្រាប់កម្ពុជា ផ្ទៃដីដាំកៅស៊ូសព្វថ្ងៃគឺមាន ៤៣៦.៦៤២ ហិចតា នៅក្នុងនោះ កំពុងតែប្រមូលផល គឺមានចំនួន ប្រមាណជា ២០១.៩៤៩ ហិចតា។ ហើយកាលពីឆ្នាំទៅ នេះ កម្ពុជានាំចេញកៅស៊ូបានប្រមាណជា ២១៧.៥០០ តោន នៅក្នុងទឹកប្រាក់ប្រមាណជា ២៨៧ លានដុល្លារ។ តម្លៃកៅស៊ូកម្ពុជានាំចេញគឺ នៅក្នុងតម្លៃជាមធ្យម ១.៣១៩ ដុល្លារ នៅក្នុងមួយតោន៕

# ព្រះសហគមន៍ផ្តល់សេវាសុខភាព ឥតគិតថ្លៃដល់ជនក្រីក្រ

*ដោយៈ រឿន ស្រីម៉ាច*



*ប្រជាជនក្នុងសហគមន៍ទទួលការពិនិត្យពីក្រុមគ្រូពេទ្យ។ រូបភាពៈ ព្រះសហគមន៍កំពង់ចាម*

ព្រះសហគមន៍កាតូលិកតែងតែយកចិត្តទុកដាក់ជាមួយជនចាស់ជរា និងកុមារក្រក្រី ដោយមានកម្មវិធីពិនិត្យជំងឺជូនពួកគាត់ និងចែកថ្នាំដោយឥតគិតថ្លៃ កាលពីថ្ងៃទី២២កុម្ភៈកន្លងទៅ នៅព្រះវិហារសន្តប្រាំង់ស្វ័រ និងសន្តីក្លារាអាស៊ីស៊ី ដែលស្ថិតនៅក្នុងភូមិកោះរការក្រៅ ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

លោកបូជាចារ្យផាន បូរី បូជាចារ្យទទួលបន្ទុកនៅក្នុងព្រះសហគមន៍កាតូលិកកោះរការបានឲ្យដឹងថា ជារៀងរាល់២ខែម្តង ក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ព្រះសហគមន៍កាតូលិកពីភ្នំពេញ តែងតែមកពិនិត្យជំងឺទូទៅបែបនេះ ជូនដល់អ្នកក្រក្រីមួយចំនួនក្នុងភូមិកោះរការនេះ។

លោកបន្តថា អ្នកជំងឺទាំងនោះគឺភាគច្រើនជាពុទ្ធបរិស័ទដែលជាអ្នកក្រីក្រគ្មានលទ្ធភាព ទៅពិនិត្យសុខភាព និងទិញថ្នាំសង្កូវផ្សេងៗ។ ហេតុនេះកម្មវិធីពិនិត្យសុខភាពនេះគឺជួយសម្រួលការចំណាយខាងផ្នែកសុខភាពរបស់ពួកគាត់ចំនួនដែរ។

ក្នុងរយៈពេលមួយថ្ងៃនោះ មានមនុស្សចាស់ និងកុមារចំនួន៨៥នាក់បានមកពិនិត្យជំងឺ។

លោកបូរីបន្ថែមថា ការមកពិនិត្យជំងឺនេះគឺពួកគាត់ទទួលបានទាំងថ្នាំ ការពិនិត្យសុខភាព និងការលើកទឹកចិត្តពីសំណាក់គ្រូពេទ្យ។ តាមការសង្កេតរបស់លោកបូជាចារ្យរូបនេះ បានឲ្យដឹងទៀតថា «អ្នកមកទទួលសេវាពិនិត្យសុខភាពទាំងនោះសប្បាយចិត្តខ្លាំង ទោះបីជាគាត់មិនស្គាល់ព្រះសហគមន៍ច្បាស់ក៏ដោយ។ តែគាត់ដឹងថាសកម្មភាពនេះគឺជាសេចក្តីស្រលាញ់ដោយឥតសំណងរបស់ព្រះសហគមន៍កាតូលិកតាមតែអាចធ្វើទៅបាន»។

ក្រោយការពិនិត្យជំងឺរួច ឃើញថាភាគច្រើនអ្នកដែលមកពិនិត្យជំងឺគឺមានជំងឺទឹកនោមផ្អែម។

កម្មវិធីពិនិត្យជំងឺនេះ មានរយៈពេលបីថ្ងៃ ដែលក្នុងមួយថ្ងៃៗក្រុមគ្រូពេទ្យស្ម័គ្រចិត្ត បានចុះទៅកាន់ព្រះសហគមន៍ផ្សេងៗគ្នា រួមមានព្រះសហគមន៍ចម្លាក់ ព្រះសហគមន៍ព្រៃទទឹង និង ព្រះសហគមន៍កោះរការ ដោយក្នុងនោះសរុបទាំងអស់មានចំនួន១៥០នាក់៕



*សកម្មភាពពិនិត្យជំងឺរបស់គ្រូពេទ្យស្ម័គ្រចិត្ត។ រូបភាពៈ ព្រះសហគមន៍កំពង់ចាម*



*ប្រជាពលរដ្ឋមកទទួលការពិនិត្យសុខភាពពីគ្រូពេទ្យស្ម័គ្រចិត្ត។ រូបភាពៈ ព្រះសហគមន៍កំពង់ចាម*

# យុវជន យុវនារី កាតូលិកបង្ហាញជំនឿ ដោយដើរចម្ងាយជិត២០គីឡូម៉ែត្រ




*ដំណើរបូជនីយស៍នៅខេត្តកំពង់ធំ រៀបចំដោយការិយាល័យ យុវជន ជំទង់ និងកុមារ ភូមិភាគភ្នំពេញ ក្រោមការណែនាំពីលោកអភិបាល អូលីវីយេ ឆ្មឹតអឺស្លែរ។ រូបភាពៈ សុធីរិទ្ធ*

*ដោយៈ ដាលីស*

យុវជន យុវនារី និងគ្រីស្តបរិស័ទប្រមាណ២៥០នាក់នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានធ្វើដំណើរបូជនីយេសក៏នៅខេត្តកំពង់ធំ រៀបចំដោយការិយាល័យ យុវជន ជំទង់ និងកុមារ ភូមិភាគភ្នំពេញ ពីថ្ងៃទី២៥ដល់ថ្ងៃទី២៧ មករា ២០១៩ ក្រោមការណែនាំពីលោកអភិបាល អូលីវីយេ ឆ្មឹតអឺស្លែរ។

លោក ស៊ាន់ សារឿន ប្រធានការិយាល័យ យុវជន ជំទង់ និងកុមារ បានឲ្យដឹងថា បូជនីយេសក៏ចរនេះគឺជាលើកទី៩ ដោយថ្មើរជើងចំងាយ ១៩គីឡូម៉ែត្រ ពីព្រះសហគមន៍ភូមិប៉ាងទៅកាន់ព្រះសហគមន៍តាំងគោក ក្នុងខេត្តកំពង់ធំ ជាដឹមរណាសាក្សីនៃព្រះសហគមន៍កាតូលិកកម្ពុជា។ បូជនីយេសក៏នេះ ធ្វើឡើងលើប្រធានបទ «នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ!» (លក ១,៣៨) ស្របតាមទិវាយុវជនទូទាំងពិភពលោក នៅប្រទេសប៉ាណាម៉ា។

លោក សារឿន បានបន្ថែមថា បូជនីយចរនេះ គឺដើម្បីបង្ហាញពីជំនឿ និងសេចក្តីសង្ឃឹមតាមរយៈការអធិដ្ឋាន។ «យើងឃើញថា នៅពេលយើងដើរ បងប្អូន(ប្រជាជន) គាត់ចាប់អារម្មណ៍ខ្លះគាត់សួរយើងថា យើងកំពុងធ្វើអី ហើយដើរពីណាមក ដើរធ្វើអី ជាដើម។» លោកសារឿនបញ្ជាក់។

ការធ្វើដំណើរនេះ ត្រូវចំណាយពេល៦ម៉ោង ពីព្រឹករហូតដល់រសៀល ដែលក្នុងនោះត្រូវបានបែងចែកជាបីដំណាក់កាល។ ក្នុងដំណាក់កាលនីមួយៗ យុវជន យុវនារី ទាំងអស់បានទទួលការអប់រំពីលោកអភិបាល អូលីវីយេ ទាក់ទងនឹងការស្គាល់ខ្លួនឯង ការជ្រើសរើសជនគំរូសម្រាប់ជីវិតរស់នៅ និងការកំណត់ទិសដៅរបស់ខ្លួន ដោយផ្សារភ្ជាប់ជាមួយជំនឿយ៉ាងរឹងមាំ ដើម្បីប្រកាសដំណឹងល្អ និងស្រឡាញ់អ្នកដទៃដូចព្រះយេស៊ូបានស្រឡាញ់មនុស្សលោក។



*គ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញធ្វើដំណើរបូជនីយេសក៍នៅខេត្តកំពង់ធំ។ រូបភាពៈ ស៊ីអេសស៊ី*

នៅថ្ងៃបិទបញ្ចប់នៃកម្មវិធីលោកអភិបាលបានថ្វាយអភិបូជាបិទ ដោយរំលឹកអំពីជីវិតអស់លោកដែលបានស្លាប់ដោយសារជំនឿក្នុងរបបប្រល័យពូជសាសន៍ប៉ុល ពត មានលោកអភិបាលឆ្មារ សាឡាស លោកបូជាចារ្យឆ្មារ សាឡឹម លោកបូជាចារ្យទ្រឿង សំអើន ជាដើម ជាគំរូនៃជំនឿសម្រាប់គ្រីស្តបរិស័ទ។ អភិបូជានេះបានធ្វើឡើងក្នុងខ្ទមដែលដាក់គ្រែរបស់អស់លោកដែលបានថ្វាយអភិបូជារួមគ្នាមុនពេលបាត់ដំណឹងឬទទួលមរណភាព។

លោកអភិបាលមានប្រសាសន៍ថា៖ «យើងមានឧបសគ្គនៅក្នុងជីវិត តែសំខាន់សូមឲ្យយើងការពារថែរក្សាជំនឿរបស់យើង ទោះបីមានគេរិះគន់ មានគេនិយាយដើមក៏ដោយ»។

អភិបូជាបិទកម្មវិធីនេះ គឺស្របពេលទិវាយុវជនពិភពលោកត្រូវបានបិទបញ្ចប់ផងដែរ។

បន្ទាប់ពីបញ្ចប់កម្មវិធីនេះ លោក ស៊ាន់ សារឿន សូមឲ្យអ្នកចូលរួមទាំងអស់បន្តការអធិដ្ឋានដល់យុវជនកម្ពុជា ក៏ដូចជាយុវជនទូទាំងពិភពលោក។

លោកក៏រំពឹងថា៖ «អ្នកដែលចូលរួមនឹងទទួលបាននូវអ្វីដែលថ្មី និងមានជំនឿរឹងមាំថែមទៀត ដើម្បីបម្រើព្រះសហគមន៍ និងសង្គម ដោយចែករំលែកសេចក្តីស្រឡាញ់ទាំងនៅក្នុងគ្រួសារ និងមនុស្សនៅជុំវិញខ្លួនផងដែរ»។

កញ្ញា ចឹម ស្រីមិច យុវនារីមកពីព្រះវិហារព្រះកុមារយេស៊ូ (បឹងទំពុន) បានឲ្យដឹងថា៖ «ខ្ញុំមានអំណរសប្បាយដែលបានដើរក្នុងព្រះនាមព្រះជាម្ចាស់ ហើយវត្តមានរបស់ព្រះជាម្ចាស់បានជួយជំរុញឲ្យខ្ញុំដើរទៅមុខ»។ នាងប្រាប់ទៀតថា នាងតែងតែមកចូលរួមកម្មវិធីនេះជារៀងរាល់ឆ្នាំដោយសារបានជួបមុខយុវជន យុវនារីថ្មីៗហើយប្រធានបទក៏ថ្មីជារៀងរាល់ឆ្នាំ។

មុនពេលបញ្ចប់កម្មវិធី លោកអភិបាល អូលីវីយេ បានប្រកាសថា ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញនឹងបន្តធ្វើបូជនីយេស៍សម្រាប់ឆ្នាំ២០២០ ទៅកាន់ភ្នំជីសូរ ដោយធ្វើដំណើររយៈពេលពីរថ្ងៃ។ បូជនីយេស៍លើកដំបូងបានចាប់ផ្តើមឡើងកាលពីឆ្នាំ២០១០៕

# ថុន រិទ្ធី៖ ខ្ញុំចង់ប្រកាសដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ដ

*ដោយៈ រឿន ស្រីម៉ាច*



រិទ្ធី វ័យ២៩ឆ្នាំមានស្រុកកំណើតនៅក្នុងភូមិក្ដុលលើ ឃុំទ្រា ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ ជាកូនទី៥ក្នុងចំណោមបងប្អូនប្រុសស្រី៦នាក់ ដែលមានឪពុកម្ដាយជាកសិករ និងជាអ្នកកាន់ពុទ្ធសាសនាប្លែកអ្វីតែយុវជនរូបនេះដែលដើរចេញមកជឿលើសាសនាគ្រីស្ដតែម្នាក់ឯងទៅវិញ?

រិទ្ធី បានប្រាប់អំពីដំណើរដើមទងនៃការផ្លាស់ប្ដូរសាសនានេះថា៖ «កាលពីខ្ញុំនៅក្មេងមិនទាន់យល់ន័យគឺមានការសម្រេចចិត្ត ស្ដាប់បង្គាប់ តាមគ្រួសារជាអ្នកឃុំគ្រង តែនៅពេលដែលខ្ញុំដឹងក្ដីហើយ គឺខ្ញុំអាចដឹងបានថា អ្វីដែលចូលចិត្ត និងអ្វីដែលមិនចូលចិត្ត ហេតុនេះការសម្រេចចិត្តគឺស្ថិតនៅលើខ្ញុំខ្លួនឯង ជាពិសេសគឺការជឿលើព្រះយេស៊ូនេះតែម្ដង»។

យុវជនរូបនេះបន្ថែមថា៖ «ខ្ញុំតែងតែឃើញចាស់ទុំយុវជន និងក្មេងៗមួយចំនួនតែងតែទៅព្រះវិហាររាល់ថ្ងៃអាទិត្យ និងក្នុងថ្ងៃបុណ្យផ្សេងៗក្នុងព្រះវិហារ ខ្ញុំតែងតែចង់ទៅចូលរួមជាមួយគេតែខ្ញុំមិនហ៊ានព្រោះខ្លាច ណាមួយត្បិតតែផ្ទះនៅជិតព្រះវិហារមែន តែមិនដែលបានទៅចូលមើលគេទេ បានតែនឹកស្រមៃក្នុងចិត្តថា ថ្ងៃណាមួយខ្ញុំនឹងចូលរួមជាមួយក្រុមនោះឲ្យបាន។

យុវជនរូបនេះបន្តថា៖ «ច្រើនថ្ងៃកន្លងផុតទៅមានក្រុមយុវជនរួមនិងលោកបូជាចារ្យបានមកសួរសុខទុក្ខផ្ទះខ្លួន ដោយមិនបានដឹងជាមុន មើលទៅទឹកមុខពួកគាត់រួសរាយរាក់ទាក់ ថែមទាំងមានបំណងជួយគ្រួសារអ្នកក្រីក្រដោយជួយឲ្យក្មេងៗមួយចំនួនក្នុងភូមិបានរៀនសូត្រ និង ស្ត្រីមេម៉ាយមានការងារធ្វើ ចាស់ជរាទទួលបានអាហារគ្រប់គ្រាន់ តាមរយៈកិច្ចការទាំងនេះបានដក់ក្នុងចិត្តខ្ញុំឲ្យចង់ក្លាយជាគ្រីស្ដបរិស័ទដូចគេដែរ។

យុវជនសម្បុរសភ្នែកតឹងដូចកូនកាត់ចិនរូបនេះបន្ថែមទៀតថា៖ «កាលពីមុន ខ្ញុំជាយុវជនឈាមរាវគឺចូលចិត្តដើរលេង និយាយស្ដីមិនសមរម្យ ខិលខូចណាស់ដែរ តែក្រោយមក ខ្ញុំបានទទួលការអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិកនេះ គឺធ្វើឲ្យជីវិតក្មេងទំនើងម្នាក់នេះបានផ្លាស់ប្ដូរស្ទើរតែទាំងស្រុង គឺយកពេលទំនេរ មកខំរៀនសូត្រ និងជួយកិច្ចការព្រះវិហារដូចជាការសួរសុខទុក្ខអ្នកក្រីក្រ អ្នកជំងឺ និង រៀបចំធ្វើនេះធ្វើនោះជាមួយយុជនផ្សេងទៀត រហូតក្លាយជាយុវជនសកម្មម្នាក់ក្នុងព្រះវិហារ។

រិទ្ធី បន្ថែមថា៖ «ក្នុងព្រះគម្ពីររាល់ពេលលោកទេសនាគឺនិយាយច្រើនអំពីសេចក្ដីស្រឡាញ់ ហេតុនេះ សេចក្ដីទាំងនោះគឺបានបង្រៀនខ្ញុំឲ្យចេះបង្ហាញសេចក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមកដោយមិនរើសអើងគ្នា ហើយចេះអត់ទោសអ្នកដែលខ្លួនស្អប់ ហើយខ្ញុំតែងតែយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងយកមករិះគិតជាប្រចាំរហូតដល់ខ្ញុំសម្រេចចិត្តបានថា ការឈានជើងចូលក្នុងរង្វង់គ្រួសាររបស់ព្រះសហគមន៏កាតូលិកគឺមានន័យណាស់សម្រាប់ខ្ញុំ»។

ក្រោយបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់នៅទីក្រុងភ្នំពេញ យុវជនរូបនេះបានប្រឡូកក្នុងវិស័យការងារមួយឆ្នាំក្នុងស្ថាប័ណមួយនៅភ្នំពេញ តែដោយសារ មើលឃើញថា ខ្លួនហាក់ដូចជាឃ្លាតឆ្ងាយពីព្រះសហគមន៏ខ្លាំងទៅៗក៏សម្រេចចិត្តមកធ្វើការជាមួយព្រះសហគមន៍កាតូលិកកំពង់ចាមផ្នែកអប់រំយុវជន និងកុមារក្នុងឆ្នាំ២០១៨។

រិទ្ធី បានឲ្យដឹងថា៖ «ដោយសារតែខ្ញុំមានទំនោរចិត្តខាងផ្នែកអប់រំជំនឿ និងការបង្ហាញសកម្មភាពជាមួយយុវជន និងកុមារ ទើបសម្រេចថាចង់បន្តធ្វើការជាមួយព្រះសហគមន៏កាតូលិក បើទោះបីជាមានប្រាក់ខែតិចជាងកន្លែងធ្វើការចាស់ក៏ពិតមែន តែអ្វីដែលទទួលបាននោះគឺភាពសប្បាយចិត្តអំណរសប្បាយ សេចក្ដីសង្ឃឹមកម្លាំងខាងផ្លូវវិញ្ញាណពេញបរិបូណ៌ ហេតុនេះ ខ្ញុំសម្រេចថានឹងខំប្រកាសដំណឹងល្អតាមរយៈកិច្ចការងាររបស់ខ្ញុំដើម្បីឲ្យព្រះសហគមន៍កាន់តែមានភាពរីកចម្រើនឡើង។

យុវជនដែលចេញមកពីទឹកដីខេត្តត្បូងឃ្មុំរូបនេះបានឲ្យដឹងបន្តថា៖ «ខ្ញុំតែងតែយកចិត្តទុកដាក់ក្នុងកិច្ចការអធិដ្ឋាន ការចូលរួមថ្វាយអភិបូជា ការស្ដាប់ព្រះបន្ទូលដំណឹងល្អជានិច្ច ព្រោះខ្ញុំដឹងថាមានតែសកម្មភាពទាំងនេះទេ ដែលជួយខ្ញុំឲ្យមានជំនឿរឹងមាំ ជាពិសេស ដើម្បីដាស់តឿនស្មារតីក្នុងនាមជាគ្រីស្ដបរិស័ទដើម្បីកុំឲ្យភ្លេចព្រះជាម្ចាស់»។

រិទ្ធី ទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០១០នៅព្រះសហគមន៍កាតូលិក ក្ដុលលើ ក្នុងភូមិភាគកំពង់ចាមហើយបានចូលរួមសកម្មភាពជាច្រើនជាមួយព្រះសហគមន៍របស់ខ្លួនដូចជា ធ្វើជាគ្រូអប់រំជំនឿ សមាជិកក្រុមយុវជន កិច្ចការរៀបចំពិធីបុណ្យផ្សេងៗក្នុងព្រះវិហារជាដើម។

ថ្លែងអំពីក្រុមគ្រួសារវិញ រិទ្ធីប្រាប់ឲ្យដឹងថា៖ «ឪពុក និងបងប្អូនរួមទាំងមិត្តភក្ដិគឺមិនពេញចិត្តក្នុងការឲ្យខ្ញុំចូលក្នុងសាសនាគ្រីស្ដនោះទេ គឺរហូតមានការទាស់សំដីជាមួយឪពុកស្ទើររាល់ថ្ងៃផងក៏មាន»។ រិទ្ធី បានបន្ថែមទៀតថា៖ «ពុកខ្ញុំប្រឆាំងដាច់ខាតអំពីការចូលគ្រីស្ដសាសនា។ គឺគាត់ជេរស្ដី បន្ទោសគ្រប់បែបយ៉ាងសឹងតែទទួលយកមិនបាន ត្បិតពួកគាត់យល់ច្រឡំថា សាសនា រឺការជឿលើព្រះយេស៊ូមិនឲ្យគោរពឪពុកម្ដាយ ចាស់ទុំ និង ការអុជធូបទានជាដើម ហើយណាមួយ សាសនានេះនាំមុខដោយជនបទេសផងនោះ រឹតតែធ្វើឲ្យពួកគាត់យល់ថាបរទេសនិយមផងដែរ ក្នុងគ្រានោះ គឺមានតែម្ដាយម្នាក់គត់ដែលនៅគាំទ្រនិងលើកទឹកចិត្តខ្ញុំឲ្យបន្តជំនឿរបស់ខ្លួនទៀត»។

រិទ្ធី បន្តថា៖ «ខ្ញុំតែងតែព្យាយាមចូលទៅជិតឪពុកដោយការតាំងចិត្ត គឺពន្យល់គាត់តាមអ្វីដែលខ្ញុំទទួលបានពីការអប់រំជំនឿ ទោះបីជាដឹងថាគាត់មិនយល់ព្រមមែន តែបន្តិចម្ដងៗខ្ញុំគិតថា គាត់ច្បាស់ជាស្ដាប់ការសុំរបស់ខ្ញុំ ទោះបីជាត្រូវប្រើពេលបន្តិចមែន។ នៅទីបំផុតឪពុកបែជាស្រលាញ់ខ្ញុំដោយយល់ចិត្ត និងដាស់តឿនខ្ញុំឲ្យទៅព្រះវិហារថែមទៀតថា នេះជាការបំភ្លឺផ្លូវពីព្រះជាម្ចាស់ពិតមែន»។

ក្នុងពេលបម្រើការនៅក្នុងព្រះសហគមន៏កាតូលិក យុវជនរូបនេះកាន់តែមានភាពជិតស្និទជាមួយមនុស្សជាច្រើននៅជុំវិញខ្លួន ជាពិសេសសកិច្ចការប្រកាសដំណឹងល្អ ហើយបានតាំងចិត្តខ្លួនយ៉ាងមុតមាំថា «ខ្ញុំចង់ក្លាយជាបូជាចារ្យម្នាក់ ព្រោះខ្ញុំគិតថា នៅប្រទេសកម្ពុជានៅមានបូជាចារ្យតិចណាស់ ហេតុនេះ ដោយក្ដីស្រលាញ់ព្រះជាម្ចាស់ ខ្ញុំចង់ថ្វាយខ្លួនបម្រើព្រះសហគមន៏ដោយប្រកាសដំណឹងល្អអស់មួយជីវិត ហើយខ្ញុំនឹងស្វែងរកផ្លូវដើម្បីបានរៀនអប់រំខ្លួនរហូតបានក្លាយជាបូជាចារ្យ ទោះបីជាមានការលំបាកក្ដី ប្រសិនបើព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ សូមឲ្យខ្ញុំមានជំនឿរឹងមាំដើម្បីអាចសម្រេចគោលដៅនេះបាន»។

តែទោះបីជាមានការតាំងចិត្តខ្ពស់ក្នុងការចង់រៀនធ្វើជាបូជាចារ្យយ៉ាងនេះក្ដីក៏យុវជនរូបនេះសូមឲ្យគ្រីស្ដបរិស័ទទាំងអស់ជួយអធិដ្ឋានសម្រាប់ខ្លួនក្នុងការសម្រេចចិត្តនេះដើម្បីអាចទៅដល់គោលដៅ និងមានជំនឿរឹងមាំថែមទៀត។

រិទ្ធី បន្ថែមទៀតថា៖ «បញ្ហាអ្វីក៏ត្រូវតែមានច្រកចេញ ហេតុនេះសូមអ្នកដែលចង់ឈ្វេងយល់អំពីជំនឿទាំងអស់កុំរលំរអែកក្នុងការសាកល្បងជឿទុកចិត្តលើព្រះជាម្ចាស់គ្រប់កិច្ចការទាំងអស់នោះទ្រង់នឹងបង្ហាញផ្លូវឲ្យយើងឃើញ ហេតុនេះសូមកុំខ្លាចអី អ្នកមានសេរីភាពក្នុងការជ្រើសរើសសាសនាដែលខ្លួនពេញចិត្តតែសំខាន់ត្រូវសួរខ្លួនឯងថា នណាជាព្រះរបស់ខ្ញុំពិតប្រាកដ?

# អាមេរិកប្រកាសលុបចោលភាពអនុគ្រោះពាណិជ្ជកម្មដល់ឥណ្ឌានិងតួកគី

ទីភ្នាក់ងារតំណាងពាណិជ្ជកម្មអាមេរិកបានអះអាងថា រដ្ឋាភិបាលអាមេរិកបានសម្រេចចិត្តលុបចោលភាពអនុគ្រោះផ្នែកពាណិជ្ជកម្មដែលបានផ្តល់ដល់ប្រទេសឥណ្ឌា និងតួកគី។

ប្រភពដដែលបានអះអាងថា នេះគឺជាការសម្រេចចិត្តរបស់រដ្ឋាភិបាលអាមេរិកក្រោមរដ្ឋបាលរបស់ប្រធានាធិបតីដូណាល់ត្រាំ។

រដ្ឋាភិបាលក្រុងវ៉ាស៊ីនតោនមានគោលបំណងលុបចោលនូវស្ថានភាពអនុគ្រោះពាណិជ្ជកម្មដល់ឥណ្ឌានិងតួកគី ខណៈដែលមហាអំណាចនេះកំពុងតែជាប់ដៃធ្វើសង្គ្រាមពាណិជ្ជកម្មជាមួយនឹងចិននៅឡើយ។

ប្រភពដដែលបានអះអាងថា អាមេរិក «មានបំណងបញ្ចប់ស្ថានភាពអនុគ្រោះពាណិជ្ជកម្មរបស់ឥណ្ឌានិងតួកគីក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ក្រោមកម្មវិធីប្រព័ន្ធអនុគ្រោះទូទៅ (GSP) ពីព្រោះពួកគេលែងអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលមានលក្ខណៈស្របច្បាប់ទៀតហើយ»។

សេចក្តីថ្លែងការណ៍បានបន្ថែមទៀតថា ប្រទេសឥណ្ឌាបានខកខានក្នុងការផ្តល់ការធានាថាខ្លួននឹងអនុញ្ញាតឲ្យមានការចូលទីផ្សារដែលគេទាមទារឲ្យមាន ខណៈប្រទេសតួកគីមានការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់គ្រាន់ ដូច្នេះប្រទេសនេះលែងមានសិទ្ធិទទួលបានស្ថានភាពអនុគ្រោះទៀតហើយ។



ប្រព័ន្ធកាំជ្រួចការពារដែនអាកាស S400 របស់រុស្ស៊ី ដែលគេជឿថាជាមូលហេតុចំបងនៃការលុបចោលភាពអនុគ្រោះពាណិជ្ជកម្ម។ រូបភាព៖ សារព័ត៌មាន RT

នៅក្រោមកម្មវិធី GSP «ផលិតផលមួយចំនួន» អាចចូលទៅអាមេរិកដោយមិនយកពន្ធ ប្រសិនបើប្រទេសនានាបំពេញតាមលក្ខណៈវិនិច្ឆ័យដែលអាចទទួលយកបានរួមទាំងការផ្តល់ឲ្យសហរដ្ឋអាមេរិកនូវលទ្ធភាពចូលទីផ្សារស្មើភាពគ្នានិងសមហេតុផល។

នេះគឺជាហេតុផលនៃការប្រកាសបញ្ចប់នូវភាពអនុគ្រោះពាណិជ្ជកម្មរបស់អាមេរិក ប៉ុន្តែហេតុផលពិតប្រាកដ គឺអាចមិនមែនដោយសារតែបញ្ហានេះទេ គឺដោយសារតែប្រទេសទាំងពីរ បានចុះកិច្ចព្រមព្រៀងទិញប្រព័ន្ធកាំជ្រួចការពារដែនអាកាស S400 របស់រុស្ស៊ី ខណៈដែលអាមេរិកបានព្រមានប្រទេសទាំងពីរជាបន្តបន្ទាប់រួចមក៕

# បញ្ជីកំពូលមហាសេដ្ឋីផុតលេខលើពិភពលោកត្រូវបានប្រកាសទៀតហើយ

បញ្ជីមហាសេដ្ឋីផុតលេខលើពិភពលោកដែលចងក្រងដោយទស្សនាវដ្តី ហ្វប (Forbes) ឆ្នាំ ២០១៩ បានចេញទៀតហើយ ដោយលោកជេហ្វ បេហ្សូស នៅតែជាមហាសេដ្ឋីដែលមានទ្រព្យសម្បត្តិច្រើនជាងគេ បន្ទាប់មក មានលោកប៊ីល ហ្គេត និងលោកវ៉ារិន បាហ្វហ្វេត។

បើយោងតាមបញ្ជី ដែលទស្សនាវដ្តី នេះបានប្រកាសកាលពីថ្ងៃទី៥ខែមីនាបានឲ្យដឹងថា ទ្រព្យសម្បត្តិរបស់លោក បេហ្សូស មានអាយុ ៥៥ ឆ្នាំបានកើនឡើងចំនួន ១៩ ពាន់លានដុល្លារក្នុងរយៈពេល១ឆ្នាំ ហើយបច្ចុប្បន្ននេះ គាត់មានទ្រព្យសម្បត្តិចំនួន ១៣១ ពាន់លានដុល្លារ។

លោកបេហ្សូស ដែលមានភាគហ៊ុន ១៦ ភាគរយក្នុងក្រុមហ៊ុន Amazon ហើយដែលទ្រព្យសម្បត្តិរបស់គាត់ឥឡូវនេះបានធ្វើឲ្យគាត់ក្លាយជាគោលដៅរបស់ពួកឆ្វេងនិយមរបស់គណបក្សប្រជាធិបតេយ្យរបស់អាមេរិកនោះ បានពង្រីកគម្លាតទ្រព្យសម្បត្តិកាន់តែធំខ្លាំងឡើងរវាងរូបគាត់និងមហាសេដ្ឋីចិត្តសប្បុរសនិងជាសហស្ថាបនិករបស់ Microsoft លោក ប៊ីល ហ្គេត។

ទស្សនាវដ្តីនេះ បានអះអាងថា លោកហ្គេតអាយុ ៦៣ ឆ្នាំបានកើនទ្រព្យសម្បត្តិដល់ ៩៦,៥ ពាន់លានដុល្លារ។

ចំណាត់លេខ ៣ គឺកាន់កាប់ដោយលោកវ៉ារិន បាហ្វហ្វេត អាយុ ៨៨ ឆ្នាំ។ លោកត្រូវបានគេចាត់ទុកថាជាកំពូលអ្នកវិនិយោគជាយូរមកហើយ ប៉ុន្តែលោកបានទទួលរងការខាតបង់កាលពីចុងខែកុម្ភៈដោយសារការធ្លាក់ចុះយ៉ាងខ្លាំងក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនផលិតអាហារកែច្នៃអាមេរិក ដែលលោកបានបណ្តាក់ទុន។

នាយកប្រតិបត្តិនៃក្រុមហ៊ុនលក់ផលិតផលប្រណីតរបស់បារាំងLVMH លោកប៊ីណាត អាណុល ឈរនៅលំដាប់លេខ ៤ ខណៈ លោកហ្សាក់ យើប៊ឺក ស្ថាបនិកហ្វេសបុក បានខាតបង់ទ្រព្យសម្បត្តិសុទ្ធចំនួន ៩ ពាន់លានដុល្លារ និងបានធ្លាក់ចុះពីលេខ ៥ មកលេខ ៨ ហើយលោកក៏បាត់បង់ជំណែងជាកំពូលមហាសេដ្ឋីក្មេងជាងគេផងដែរ។

អ្នកដែលនាំមុខលោកហ្សាក់យើប៊ឺកឥឡូវនេះគឺមហាសេដ្ឋីម៉ិកស៊ិក លោកខាឡូស ស្លីម លោកអាម៉ាន់ស៊ីអូ អូតេហ្គា ជនជាតិអេស្ប៉ាញ ដែលជាសហស្ថាបនិករបស់ក្រុមហ៊ុន Zara and Inditex និងលោកឡារី អែលលីសុន សហស្ថាបនិកក្រុមហ៊ុន Oracle៕




តារាងបញ្ជីឈ្មោះមហាសេដ្ឋីពិភពលោកថ្មីឆ្នាំ២០១៩។ រូបភាព៖ ទស្សនាវដ្តី Forbe

# ព្រះសហគមន៍កាតូលិកកោះរការសាងសង់ផ្ទះជូនស្ត្រីមេម៉ាយ

*ដោយៈ រឿន ស្រីម៉ាច*

កាលពីថ្ងៃទី៣ ខែមីនាកន្លងទៅ ព្រះសហគមន៍កាតូលិកសន្តហ្វ្រង់ស័រ និង សន្តីក្លារាអាស៊ីស៊ី( កោះរការ ) ដែលស្ថិតនៅក្នុងភូមិកោះរការក្រៅ ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានកំពុងសាងសង់ផ្ទះជូនដល់ស្ត្រីមេម៉ាយម្នាក់ស្ថិតនៅក្នុងភូមិកោះប្រាក់ ឃុំ កោះសូទិន ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

លោកបូជាចារ្យ ផាន បូរី ជាបូជាចារ្យទទួលបន្ទុកព្រះសហគមន៍នេះបានមានប្រសាសន៍ថា ផ្ទះឈើនេះ មានទំហំ៥x៨ម៉ែត ប្រកស័ង្កសីជូនដល់ស្ត្រីមេម៉ាយកូនពីរដែលមានជីវភាពទីទ័លក្រ មានមុខរបរស៊ីឈ្នួលដើរបេះម្ទេសឲ្យគេដោយក្នុងមួយថ្ងៃអាចរកកម្រៃបានតែ១ម៉ឺនរៀលតែប៉ុណ្ណោះ។

លោកបូជាចារ្យរូបនេះបន្ថែមថា ដោយសារតែឃើញគាត់គ្មានផ្ទះជ្រកកោន លំបាកពេក ណាមួយគាត់ជាស្រីទន់ខ្សោយ ហេតុនេះ ព្រះសហគមន៍បានប្រមូលថវិការខ្លះៗដែលមានតាមរយៈសប្បុរសជនប្រាក់ដង្វាយ និងការលក់នំខ្លះៗពេលមានពិធីបុណ្យរបស់ក្រុមយុវជននាពេលកន្លងមក ដើម្បីយកមកទិញសម្ភារៈធ្វើផ្ទះមួយនេះឡើងគឺសរុបជាទឹកប្រាក់៦០០ដុល្លា ដោយមានការជួយពីសំណាក់អ្នកភូមិ និងគណៈកម្មការមួយចំនួនពីព្រះសហគមន៍ផងដែរ។

លោក បូរី ក៏បានបញ្ជាក់ផងដែរថា៖ «ព្រះសហគមន៍មិនមែនជាឃ្លាំងលុយសម្រាប់ជួយអ្នកនេះអ្នកនោះតាមការនឹកឃើញ តែអ្វីដែលមានគឺជាប្រាក់សន្សំសម្រាប់ជួយអ្នកដែលត្រូវការជាចាំបាច់ គឺអ្នកក្រីក្រ។ ហេតុនេះទោះបីអ្នកនោះមានសាសនាអ្វី គឺយើងជួយគេដោយក្តីស្រលាញ់ហើយក៏មិនមែនអូសទាញគេឲ្យចូលសាសនាខ្លួនឡើយ។ តែផ្ទុយទៅវិញចង់ឲ្យអ្នកទាំងនោះមានអំណរសប្បាយហើយគិតថាមានមនុស្សជាច្រើនដែលកំពុងស្រឡាញ់គេ មិនបោះបង់គេចោល»។



*ព្រះសហគមន៍កាតូលិកសន្តហ្វ្រង់ស័រ និង សន្តីក្លារាអាស៊ីស៊ី សង់ផ្ទះជូនស្ត្រីមេម៉ាយក្រីក្រ។ រូបភាពៈ ព្រះសហគមន៍កាតូលិក*

អ្នកស្រី ភួង សុភី វ័យ ៥៦ឆ្នាំ ទទួលបានផ្ទះថ្មី១ខ្នង ពីព្រះសហគមន៍កាតូលិកបានឲ្យដឹងដែរថា៖ «ខ្ញុំសូមអរគុណជាខ្លាំងចំពោះព្រះសហគមន៍កាតូលិកដែលបានជួយស្រោចស្រង់ជីវិតរបស់ខ្ញុំឲ្យមានផ្ទះរស់នៅដូចគេឯង បើគ្មានការជួយពីលោកទេ មិនដឹងថាពេលណាមានដំបូលជ្រកនោះទេ»។

អ្នកស្រី សុភី ជាស្ត្រីមេម៉ាយដែលមានកូន២នាក់ក្នុងបន្ទុក បន្ថែមទៀតថា៖ «ជីវិតខ្ញុំក្រីក្រខ្លាំងរស់នៅរាល់ថ្ងៃពឹងអាស្រ័យតែបងប្អូន និងអ្នកជិតខាងខ្លះៗ តែខ្ញុំទទួលបានក្តីសង្ឃឹមខ្លាំងនៅពេលដែលឃើញខាងព្រះសហគមន៍មកសួរសុខទុក្ខ និងផ្តល់ជំរកឲ្យខ្ញុំ និងកូនៗ។ វាមិនច្រើនទេ សម្រាប់អ្នកមានតែវាច្រើនខ្លាំងណាស់សម្រាប់ជីវិតខ្ញុំជាអ្នកក្រីក្រហេតុនេះមេរៀនក្តីស្រលាញ់ដែលខ្ញុំទទួលបានពីខាងសាសនាកាតូលិកមកលើគ្រួសារខ្ញុំ និងអ្នកក្រីក្រផ្សេងទៀត។ នេះគឺធ្វើឲ្យខ្ញុំមានកម្លាំងចិត្តរស់នៅបន្តហើយ និងអនុវត្តនូវការជួយគ្នាទៅវិញទៅមកដោយក្តីស្រលាញ់ដូចខ្ញុំបានទទួលដែរ»។

លោកបូជាចារ្យក៏សូមលើកទឹកចិត្តដល់អ្នកក្រីក្រ អ្នកជំងឺ និងអ្នកដែលកំពុងពិបាកចិត្តទាំងអស់ថា៖ «សូមឲ្យមានសេចក្តីសង្ឃឹមក្នុងជីវិត ត្រូវប្រឹងប្រែងរស់នៅបន្តទៀត ត្រូវប្រឹងប្រែងធ្វើការ បើទោះបីជាយើងជាអ្នកក្រ ជាមនុស្សដែលគេមិនចង់រាប់រក តែនៅមានមនុស្សជាច្រើនដែលស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះយើងជាពិសេសគឺព្រះជាម្ចាស់ដែលតែងតែស្រឡាញ់អ្នកក្រីក្រគ្រប់ពេលវេលា ក្នុងអង្គព្រះគ្រីស្តយើងជាមហាគ្រួសារតែមួយ៕

# គ្រូអប់រំជំនឿថ្វាយពាក្យសច្ចានៅបាត់ដំបងក្រុង

*ដោយៈ រឿន ស្រីម៉ាច*

ក្រុមអ្នកណែនាំជំនឿ នៃព្រះសហគមន៍បាត់ដំបងក្រុង បានធ្វើពិធីថ្វាយពាក្យសច្ចារបស់ខ្លួន ជាការស្ម័គ្រចិត្តក្នុងការចែករំលែក និងណែនាំជំនឿបន្តដល់អស់អ្នកដែលចង់ស្គាល់អំពីគ្រីស្តសាសនានិកាយកាតូលិក កាលពីថ្ងៃទី១៧ កុម្ភៈ នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នៅបាត់ដំបងក្រុង។

ជាទូទៅព្រះសហគមន៍នៅក្រុងបាត់ដំបងតែងតែធ្វើពិធីថ្វាយពាក្យសច្ចារបស់អ្នកណែនាំជំនឿនេះ ជារៀងរាល់ពីរឆ្នាំម្តង ដើម្បីបើកវគ្គសិក្សាអប់រំជំនឿថ្មី។ ក្នុងឆ្នាំនេះ មានគ្រូចូលរួមស្ម័គ្រចិត្តចំនួន៣៨នាក់ ដោយទទួលស្គាល់ជាផ្លូវការពីលោកអភិបាលអេនរីគេ ហ្វីកាវេដូនៃព្រះហាសគមន៍បាត់ដំបងក្រុង។



*ក្រុមអ្នកណែនាំជំនឿធ្វើពិធីថ្វាយពាក្យសច្ចារក្នុងការចែករំលែក និងណែនាំជំនឿបន្ត។ រូបភាពៈ ព្រះសហគមន៍បាត់ដំបង*

តាមប្រសាសន៍របស់អ្នកស្រី ស្រីសុ ជុំ ជាមន្ត្រីទំនាក់ទំនងព្រះវិហារបាត់ដំបងក្រុងបានឲ្យដឹងថាកម្មវិធីថ្វាយពាក្យសច្ចានេះ ជាការដាស់តឿនដល់គ្រូអប់រំជំនឿអំពីកាតព្វកិច្ចបញ្ជូនបន្តជំនឿដោយភាពត្រឹមត្រូវ និងក្តីស្រឡាញ់នៅចំពោះមុខព្រះជាម្ចាស់។

អ្នកស្រីបន្ថែមថា៖ «ហេតុនេះ ទោះជាមានការលំបាកអ្វីក៏កុំបោះបង់កិច្ចការនេះចោល ព្រោះវាជាផ្លូវតែមួយគត់ដើម្បីអ្នកផ្សេងបានស្គាល់ព្រះជាម្ចាស់»។

នៅក្នុងពិធីថ្វាយពាក្យសច្ចានេះផងដែរ លោកអភិបាលអេនរីគេ ហ្វីកាវេដូ នៃព្រះសហគមន៍ភូមិភាគបាត់ដំបងបានសូមឲ្យគ្រូអប់រំក៏ដូចជាគ្រីស្តបរិស័ទទាំងអស់រិះគិតនូវចំណុចសំខាន់ៗរួមមាន៖

*១. សូមឲ្យរស់នៅតាមរបៀបគ្រីស្តបរិស័ទដោយយកព្រះបន្ទូលជាទីពឹង*
*២. អធិដ្ឋានជាប្រចាំ*
*៣. កែប្រែចិត្តគំនិត។*

លោកអភិបាលបន្ថែមថា៖ «ក្នុងនាមជាគ្រីស្តបរិស័ទប្រហែលមានកិច្ចការមួយចំនួនធ្វើឲ្យយើងពិបាកក្នុងការប្រតិបត្តិ តែចំណុចខ្លះៗដែលខ្ញុំលើកឡើងខាងលើគឺជាការដាស់តឿន ដើម្បីកុំឲ្យយើងភ្លេចថាខ្លួនជានណា ហើយត្រូវធ្វើអ្វីខ្លះ ដើម្បីរក្សា និងបញ្ជូនបន្តជំនឿ»៕

# យុវជនកំពង់ចាម ធ្វើបូជនីយចររិះគិតជំនឿ

**យុវជនយុវនារីតំបន់កំពង់ចាមក្រុង៦០នាក់ បានរួមគ្នាធ្វើបូជនីយចរ ដើម្បីរិះគិត និងពង្រឹងជំនឿរបស់ខ្លួនបន្ថែមទៀត ដោយហែរឈើឆ្កាង និងសូត្រផ្គាំនៅលើចម្ងាយផ្លូវ១៣គីឡូម៉ែត្រ ពីព្រះសហគមន៍កាតូលិកបុសខ្នុរ ទៅដីចំការព្រះសហគមន៍ក្នុងស្រុកចំការលើ កាលពីថ្ងៃទី១៩ កុម្ភៈ កន្លងទៅ។**



*យុវជនយុវនារីតំបន់កំពង់ចាមក្រុងបានរួមគ្នាធ្វើបូជនីយចរដើម្បីរិះគិត និងពង្រឹងជំនឿ។ រូបភាព៖ .....*

*ដោយៈ រឿន ស្រីម៉ាច*

តាមប្រសាសន៍របស់លោកបូជាចារ្យ សែ សាត ដែលជាបូជាចារ្យទទួលខុសត្រូវ នៅព្រះសហគមន៍កំពង់ចាមនឹងបានដឹកនាំកម្មវិធីអធិដ្ឋានដោយថ្មើជើងនេះបានឲ្យដឹងថា ការអធិដ្ឋានតាមរបៀបដើររួមគ្នានៅលើដងផ្លូវនេះ គឺជួយយើងម្នាក់ៗរិះគិតអំពីជំនឿ និងទុក្ខលំបាករបស់ព្រះយេស៊ូផង និងរំលឹកអំពីព្រះនាងម៉ារីដែលជាមាតានៃជំនឿផង។

លោកបូជាចារ្យ សែ សាត ថ្លែងឲ្យដឹងថា៖ «ហេតុនេះ ក្រោមពន្លឺថ្ងៃ និងការហត់នឿយអស់កម្លាំង និងការចំណាយពេលវេលានេះ គឺឲ្យយើងម្នាក់ចេះស៊ូទ្រាំ និង តាំងចិត្តអធិដ្ឋាន បើទោះបីជាមានបញ្ហាអ្វីក្នុងជីវិតក៏ដោយត្រូវតែជំនះ ហើយដើរទៅមុខទៀតដើម្បីប្រកាសជំនឿថា ខ្ញុំចង់ដើរតាមព្រះយេស៊ូដើម្បីប្រកាសដំណឹងល្អរបស់ព្រះអង្គ»។

លោកបូជាចារ្យរូបនេះបន្តថា នេះជាលើកទីមួយហើយដែលព្រះសហគមន៍រៀបចំឲ្យមានដំណើរបូជនីយចរដោយថ្មើរជើងនេះ។ កន្លងមកព្រះសហគមន៍មានតែរបៀបអធិដ្ឋានដោយមានការចូលរួមថ្វាយអភិបូជា ការអង្គុយស្ញៀមស្ងាត់ជារបៀបតេហ្សេ ការជិះកង់ ការអធិដ្ឋាន និងរិះគិតអំពីព្រះគម្ពីរ ក្នុងកម្មវិធីសំណាក់ធម៌ផ្សេងៗប៉ុណ្ណោះ។

លោក ថុន រិទ្ធី ជាគណៈកម្មការរៀបចំបូជនីយចរនេះ ឲ្យដឹងថា បូជនីយចរនេះ គឺមានបែងចែកជា៤ដំណាក់កាល ដែលក្នុងនោះរួមមាន រិះគិតអំពីប្រភពនៃជីវិត រិះគិតអំពីព្រះពរចេញពីជំនឿ រិះគិតអំពីអ្នកជឿ និងទទួលបានការសង្គ្រោះ និងរិះគិតអំពីជំនឿទទួលព្រះជន្មរបស់ព្រះជាម្ចាស់នៃជីវិតអស់កល្បជានិច្ច។

លោក រិទ្ធី បានបញ្ជាក់ឲ្យដឹងដែរថា តាមរយៈដំណាក់កាលនីមួយៗ គឺជួយយុវជនច្រើនឲ្យគេរិះគិតអំពីជីវិតផ្ទាល់ខ្លួនផង និងជំនឿរបស់គេផង។ ហេតុនេះ កម្មវិធីបូជនីយចរ គឺហុចផលផ្លែច្រើនខាងផ្នែកជំនឿសម្រាប់យុវជន។ តាមគម្រោងការរបស់ព្រះសហគមន៍នឹងមានរៀបចំបូជនីយចរនេះជាបន្តបន្ទាប់ទៀតក្នុងឆ្នាំនេះ ទៅកាន់ព្រះសហគមន៍ផ្សេងៗក្នុងភូមិភាគកំពង់ចាមផងដែរ។ កម្មវិធីមានយុវជនមកពីព្រះសហគមន៍រលៀក ភូមិថ្មី កំពង់ចាមក្រុង មណ្ឌលយុវជន ប្រុស និងមណ្ឌលស្រី៕



*យុវជនយុវនារីរួមគ្នាធ្វើបូជនីយចរដើម្បីរិះគិតអំពីប្រភពនៃជីវិត រិះគិតអំពីព្រះពរចេញពីជំនឿ រិះគិតអំពីអ្នកជឿ និងទទួលបានការសង្គ្រោះ និងរិះគិតអំពីជំនឿទទួលព្រះជន្មរបស់ព្រះជាម្ចាស់នៃជីវិតអស់កល្បជានិច្ច។ រូបភាព៖ .....*

# ពិធីសម្ពោធ ដាក់ឱ្យប្រើប្រាស់សមិទ្ធផលនានា នៃសាលាបឋមសិក្សា និង វិទ្យាល័យបច្ចេកទេស សន្តប្រហ្វង់ស្វ័រ



*លោកអភិបាល អូលីវីយេ និងលោករដ្ឋមន្ត្រីក្រសួងអប់រំ ហង់ ជួនណារ៉ុន អញ្ជើញកាត់ខ្សែបូសម្ពោធសាលាបឋមសិក្សា និងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តប្រហ្វង់ស្វ័រ។ រូបភាពៈ សុធីរិទ្ធិ*



*លោករដ្ឋមន្ត្រីពិនិត្យអគារសិក្សាបំពាក់ដោយសម្ភារៈសិក្សាទំនើប និងសមិទ្ធិផលនានានៃសាលាបឋមសិក្សា និងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តប្រហ្វង់ស្វ័រ។ រូបភាពៈ សុធីរិទ្ធិ*

អគារសិក្សា ជាច្រើនខ្នង បំពាក់ដោយសម្ភារៈសិក្សាទំនើបគ្មានពីរ និងសមិទ្ធិផលនានានៃសាលាបឋមសិក្សាសន្តប្រហ្វង់ស្វ័រ និងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តប្រហ្វង់ស្វ័រ ស្ថិតនៅក្នុងឃុំពីរផ្សេងគ្នានៃស្រុកត្រាំកក់ ខេត្តតាកែវ ដែលជាគំនិត ផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់លោក អភិបាល អូលីវីយេ ផ្មិតហាស្លេរ បានសម្ពោធដាក់ឲ្យប្រើប្រាស់ ជាផ្លូវការហើយ កាលពីថ្ងៃទី២៩ ខែមករាឆ្នាំ២០១៩ កន្លងទៅ ក្រោមអធិបតីរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោក ហង់ ជួនណារ៉ុន។

តាមរបាយការណ៍របស់ លោក យ៉ុន សំអាត នាយកវិទ្យាល័យបច្ចេកទេស សន្តប្រហ្វង់ស្វ័របានឲ្យដឹងថា សាលាបឋមសិក្សា សន្តប្រហ្វង់ស្វ័រ មានទីតាំង ក្នុងភូមិចំការទៀងឃុំគួស មានអគារចំនួន៤ខ្នង ចំណែកឯវិទ្យាល័យបច្ចេកទេសសន្តប្រហ្វង់ស្វ័រ មានទីតាំងស្ថិតនៅភូមិអង្គគគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ មានអាគារសិក្សាចំនួន ១ខ្នង អគារអន្តេវាសិកដ្ឋានចំនួន ២ខ្នង តារាងបាល់ទាត់ស្តង់ដាមួយ សណ្ឋាគារគំរូចំនួន ១ខ្នង កញ្ចុះសម្រាប់សិស្សអង្គុយអានសៀវភៅចំនួន៤ ផ្ទៃដីកសិដ្ឋាន៥០០០ម៉ែត្រការេ និងបរិក្ខាកំប្លេ ផ្ទៃដីស្រែសម្រាប់សិស្សអនុវត្ត ៤ ហិកតា និង កសិដ្ឋានសម្រាប់ សិស្សចុះកម្មសិក្សា ចំនួន ៧០ ហិកតា នៅតំបន់អភិវឌ្ឍន៍ ភ្នំវល្លិ៍ នៅខេត្តកែបផងដែរ។

លោកអភិបាល អូលីវីយេ ផ្មិតហាស្លេរ ជាស្ថាបនិកនៃសាលាទាំងនេះបានឲ្យដឹងថាលោកកសាងសាលារៀនទាំងនេះដើម្បីចូលរួមក្នុងវិស័យអប់រំ កសាងធនធានមនុស្សដែលមានមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ឲ្យមានចំណេះជំនាញយ៉ាងច្បាស់លាស់ក្នុងកំរិតខ្ពស់។

លោកអភិបាលបានបន្តថា វិទ្យាល័យបច្ចេកទេសសន្តប្រហ្វង់ស្វ័រ ជាវិទ្យាល័យ និងមានតែមួយគត់ក្នុងខេត្តតាកែវ ដែលបណ្តុះបណ្តាលលើផ្នែកបច្ចេកទេសលើមុខជំនាញ កេរ្សត្រសាស្ត្រ និងទេសចរណ៍។

លោកថា សាលាបឋមសិក្សាសន្តប្រហ្វង់ស្វ័រ មិនគ្រាន់តែបង្រៀនចំណេះដឹងទូទៅប៉ុណ្ណោះគឺ មានបញ្ចូលម៉ោងកំព្យូទ័រច្បាស់លាស់ ម៉ោងបណ្ណាល័យ ធ្វើស្ទួនបន្លែនិងបញ្ចូលកម្មវិធីបង្រៀនសិល្បៈ ក្នុងគោលបំណងចូលរួមការពារទ្រព្យសម្បត្តិវប្បធម៌យើងដូចជា ល្ខោនខោលជាដើម...។

គួរបញ្ជាក់ឲ្យដឹងផងដែរថា សាលាបឋមសិក្សាសន្តប្រហ្វង់ស្វ័រ បានទទួលការឧបត្ថម្ភពីសប្បុរសជននៃប្រទេសសិង្ហបុរី ចំពោះវិទ្យាល័យបច្ចេកទេសសន្តប្រហ្វង់ស្វ័របានទទួលការឧបត្ថម្ភពី កាតូលិកមីសិនអូស្ត្រាលី៕

# អ្នកណែនាំជំនឿ រៀនធ្វើកិច្ចតែងការ ផ្នែកអប់រំជំនឿ



*សិក្ខាកាមដែលបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលកិច្ចតែងការផ្នែកអប់រំជំនឿ របស់មណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិកកម្ពុជា ហៅកាត់ថា CCCC ។ រូបភាពៈ ហ្វេសប៊ុក*

*ដោយៈ រឿន ស្រីម៉ាច*

មណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិកកម្ពុជា ហៅកាត់ថាCCCC បានរៀបចំកម្មវិធីបណ្តុះបណ្តាលផ្នែកគរុកោសល្យអំពីកិច្ចតែងការដល់អ្នកណែនាំជំនឿ នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារី ឡើងស្ថានបរមសុខ ក្រុងបាត់ដំបង កាលពីថ្ងៃទី១៩ ខែកុម្ភៈ ដែលមានសិក្ខាកាម១៩នាក់ចូលរួម។

សិក្ខាសាលានេះ មានរៀបចំកិច្ចតែងការមេរៀនអប់រំជំនឿ ការអានព្រះគម្ពីរដើម្បីយល់ពាក្យឃ្លោងឃ្លាផ្សេងៗ មានពាក្យពន្យល់ និងអត្ថន័យនៃគម្ពីរផ្ទាល់ និងមានការរិះគិតអំពីអត្ថន័យក្នុងគម្ពីរ។ ភាគច្រើនអ្នកណែនាំជំនឿក្នុងឆ្នាំសិក្សាថ្មីនេះ ជាអ្នកគ្មានបទពិសោធន៍ក្នុងការបង្រៀនកន្លងមកទេ។

អ្នកស្រី ស្រី សុជុំ សិក្ខាកាមម្នាក់បានឲ្យដឹងថា៖ «ខ្ញុំមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការបង្រៀនអប់រំជំនឿ។ ហេតុនេះ ធ្វើឲ្យខ្ញុំយល់បានថា ក្នុងនាមជាអ្នកណែនាំខាងផ្នែកអប់រំជំនឿ គឺត្រូវតែយល់អំពីអ្វីដែលយើងកំពុងបង្រៀនឲ្យបានច្បាស់លាស់។ ប្រសិនបើយើងនិយាយអ្វីដែលខុសពីសេចក្តីពិតឬមិនច្បាស់លាស់នូវចំណុចណាមួយនោះ នឹងធ្វើឲ្យសិស្សទទួលបានអ្វីដែលមិនច្បាស់ទៅតាមនោះដែរ»។

អ្នកស្រីបន្ថែមថា កម្មវិធីនេះ មានសារៈសំខាន់ដើម្បីឲ្យគ្រូទទួលបានចំណេះដឹងថ្មីៗផង និង ចេះរៀបចំខ្លួនដើម្បីបង្រៀនអប់រំជំនឿយ៉ាងច្បាស់លាស់ផង៕

# រូបភាពសកម្មភាពស្ដីអំពី អភិបូជាអរព្រះគុណព្រះជាម្ចាស់បុណ្យរោយផេះ



## វិទ្យុវីរីតាស់អាស៊ីខេមរភាសា

សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

Khmer Service

RADIO VERITAS ASIA-KHMER SERVICE

**វិទ្យុវីរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយវិទ្យុ FM នៅភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្ដាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com និង www.catholiccambodia.org
- លោកអ្នក ក៏អាច Follow facebook ផ្លូវការរបស់យើងតាមរយៈ www.facebook.com/RVAKHMER/

**តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្ដាប់កម្មវិធីវិទ្យុវីរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ Smart Phone ដែលប្រើប្រព័ន្ធ Android ឬប្រព័ន្ធ IOS ដោយគ្រាន់តែចូលទៅកាន់ Play Store ឬ App Store វាយពាក្យ Radio Varitas Asia រួច Download កម្មវិធីនោះដោយស្វែងរកប៊ូតុង ( Khmer Live Audio )។

Radio Varitas Asia

Khmer Live audio

ឬ តាមរយៈគេហទំព័រ៖ http://rvakhmer.com